# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

## អារម្ភកថា

២០០០ឆ្នាំប្រវត្តិសាស្ត្រនៃទឹកដីខ្មែរ គ្មានអ្នកណាម្នាក់អាចបដិសេធន៍បានថាទឹកដីខ្មែរកម្ពុជាក្រោមមិនមែនជាទឹកដីរបស់ខ្មែរនោះទេ។ ប្រជាពលរដ្ឋខ្មែរជាអ្នកកាប់ឆ្ការព្រៃកសាងទឹកដីកម្ពុជាក្រោម មុនគេបង្អស់។ ប្រជាពលរដ្ឋខ្មែរមិនមែនជាជាតិសាសន៍សោត់អណ្តែតតាមទូកតាមកាណូតវាតទីយកទឹកដីនៃប្រទេសជិតខាងនោះទេ គឺមានកំណើតកើតនៅលើទឹកដីកម្ពុជាក្រោមតែម្តង។

កម្ពុជាក្រោម កាលពីដើមឡើយហៅថា នគរហ្វូណន មានព្រះមហាក្សត្រិយានី លីវ យី និងព្រះបាទហ៊ុន ទៀន សោយរាជ្យជាបឋមក្សត្រដំបូងបង្អស់នៃរាជវង្សខ្មែរ រហូតដល់បង្កើតបានទៅជាព្រះរាជាណាចក្រកម្ពុជា នៅក្នុងគ្រឹស្តសករាជ ៥៥០ ក្រោមព្រះរាជកិច្ចដឹកនាំនៃការបង្រួបបង្រួមរបស់ព្រះករុណាព្រះបាទភវវរ្ម័ន រវាងនគរចេនឡា និងហ្វូណន គេពុំទាន់មានឃើញវត្តមាននៃជនជាតិយួននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាថ្មីនេះនៅឡើយទេ។ រហូតដល់ឆ្នាំ១៦១៨ ក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី២ ទើបឃើញមានវត្តមានជនជាតិយួនដំបូងបង្អស់នៅលើទឹកដីខ្មែរ គឺតាមរយៈការរៀបអភិសេកព្រះបាទជ័យជេដ្ឋាទី២ ជាមួយកូនស្រីទី៩ របស់ស្តេចយួនឈ្មោះ ង្វៀង សាយវឿង។

កាលពីថ្ងៃទី០៥ និងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ថ្មីនេះ លោក ត្រឹង វ៉ាន់ធុង អ្នកនាំពាក្យនៃស្ថានទូតវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា បានថ្លែងបំភ្លៃការពិតនៃប្រវត្តិសាស្ត្រខ្មែរថា ទឹកដីខ្មែរកម្ពុជាក្រោមជាទឹកដីរបស់វៀតណាមយូរហើយ ហើយដែលថាបារាំងបានកាត់ទឹកខ្មែរកម្ពុជាក្រោមឲ្យវៀតណាមពុំមានមូលដ្ឋានឡើយ។ នេះជាភាសាអ្នកការទូតវៀតណាមមើលងាយប្រជាពលរដ្ឋខ្មែរយ៉ាងខ្លាំង ដែលយើងមិនអាចទទួលបានជាដាច់ខាត។

ដើម្បីកុំឲ្យមានការបំភ្លៃបំផ្លិចប្រវត្តិសាស្ត្រតទៅទៀត អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានចងក្រងឯកសារដ៏សង្ខេបនេះជាភស្តុតាងបញ្ជាក់ជូនសាធារណមតិជាតិ-អន្តរជាតិ ជាពិសេសរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមថា ទឹកដីកម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរពិតប្រាកដមិនអាចប្រកែកបាន ការត្រួតត្រារបស់អាជ្ញាធរវៀតណាមសព្វថ្ងៃ គឺជាការត្រួតត្រាបែបអាណានិគមបន្តពីអាណានិគមបារាំងតែប៉ុណ្ណោះ ។ ប្រជាពលរដ្ឋខ្មែរនៅតែចាត់ទុកថា ទឹកដីខ្មែរកម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរ យួនកាន់កាប់សព្វថ្ងៃគឺជាការខុសច្បាប់។

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមអភ័យទោសចំពោះការមិនបានលើកយកភស្តុតាងនានាដ៏ច្រើនរាប់មិនអស់មកបញ្ជាក់ក្នុងឯកសារនេះ ដោយសារពេលវេលា និងលទ្ធភាព។ យើងខ្ញុំនឹងខិតខំស្រាវជ្រាវថែមទៀត ដើម្បីបោះពុម្ពជាសៀវភៅឲ្យបានល្អនៅពេលអនាគត។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៤

គណៈកម្មការស្រាវជ្រាវ

លោក ថាច់ សេដ្ឋា ប្រធាន លោកគឹម សកល , លោក សឺន យឿង សមាជិក លោក សឺន ជុំជួន, ព្រះតេជគុណ ពេជ្រ ប៊ុនថន,ព្រះតេជគុណឡាយ ឡាត, លោក គឹម ខាយ, លោក ថាច់ ធី, លោកថាច់ វៀង លោក ស៊ឺន សុផា អ្នកស្រី ព្រំ យ៉ាង

ទីស្នាក់ការផ្ទះលេខ: ៧២ ផ្លូវលេខ: ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ១២ ៥០៨ ៨៨២ / ៩៣ ៨៧ ៨៧ ០៦
E-mail: thachsetha13@gmail.com Website: http/khmerkromngo.org

# បុរេប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម

កាលណានិយាយពីទឹកដីកម្ពុជាក្រោម យើងមិនអាចកាត់ផ្តាច់ ដោយមិននិយាយពីព្រះរាជាណាចក្រកម្ពុជាបាននោះទេ ព្រោះកាលពីដើមឡើយ ទឹកដីកម្ពុជាក្រោមជាទឹកដីកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា។

លោក Dauphin Meunier អនុប្រធានសមាគមភូមិសាស្ត្រ និងសេដ្ឋកិច្ចបារាំង បានសរសេរអំពីបុរេប្រវត្តិសាស្ត្រខ្មែរថា ប្រជារាស្ត្រកម្ពុជា ដែលគេស្គាល់ថាជាប្រជារាស្ត្រខ្មែរនោះ បានបង្កើតឡើងដោយក្រុមអូស្ត្រូអាស៊ីយ៉ាទិក (Austro Asiatique) ហើយបានតាំងលំនៅក្នុងឧបទ្វីបឥណ្ឌូចិនប្រហែលជាម្ភៃសតវត្សរ៍មុនគ្រឹស្តសករាជ។ លោក Dauphin Meunier បានសរសេរបញ្ជាក់ថា ប្រជារាស្ត្រទាំងឡាយនៅឥណ្ឌូចិនមានតែប្រជារាស្ត្រខ្មែរទេ ដែលបានតាំងទីលំនៅមុនគេបង្អស់។ លុះដល់សតវត្សរ៍ទី១៣ ទើបឃើញមានជនជាតិអណ្ណាម សៀម និងភូមា។

លោក Andre Migot បានចម្លងឡើងវិញនូវផែនទីប្រវត្តិសាស្ត្រនិងបុរាណវិទ្យាបង្ហាញពីភាពអស្ចារ្យ មហាចក្រភពខ្មែរ ឬហៅថា កាំប៊ុយហ្សាដេសា (Empire Khmer Kambujadeca) នៅសតវត្សរ៍ ទី១១-១២-១៣ ដែលបានកាន់កាប់ស្ទើរតែទាំងស្រុងក្នុងឧបទ្វីបឥណ្ឌូចិន និងមួយភាគធំនៃទឹកដីសៀម។ លោក Andre Migot បានសរសេរបន្តថា ភាពខុសគ្នាដែលបានកើតមានឡើង រវាងប្រទេសវៀតណាម និងប្រទេសខ្មែរ មិនមែនជាភាពចៃដន្យនៃមជ្ឈដ្ឋានភូមិសាស្ត្រនោះទេ។ ការពិតជាក់ស្តែងជួរភ្នំអណ្ណាមបានខណ្ឌចែកតំបន់ពីរដាច់ដោយឡែកពីគ្នារួចទៅហើយ ហើយមនុស្ស ភាសា វប្បធម៌ សាសនា និងការរស់នៅខុសគ្នាទាំងស្រុងតែម្តង។ មានន័យថា មានពិភពពីរដាច់ដោយឡែកពីគ្នា គឺប្រទេសវៀតណាមជាពិភពចិន ប្រទេសខ្មែរជាពិភពឥណ្ឌា។

ចាប់តាំងពីសតវត្សរ៍ទី២ រហូតដល់ទី៦ នៃគ្រឹស្តសករាជ គឺជាសម័យកាលមួយហៅថា សម័យកាល Proto-Khmer បានផ្សាយគ្រប់ទិសទី។ សម័យនេះហើយ ក្រុមប្រវត្តិវិទូបានសរសេរថា ជាសម័យកាលអារ្យធម៌ខ្មែររុងរឿង និងរីកចម្រើនធំអស្ចារ្យ (សម័យហ្វូណន)។ ពេលនោះពុំទាន់មានព្រះរាជាណាចក្រកម្ពុជានៅឡើយទេ គេស្គាល់តែ*នគរហ្វូណន ឬប្រទេសហ្វូណន* ប៉ុណ្ណោះ។ ហេតុដូចម្តេចបានជានគរហ្វូណនល្បីល្បាញខ្លាំងម្ល៉េះ កាលសម័យនោះ?

លោក Louis Malleret បុរាណវិទូជំនើម បានសរសេរ និងបោះពុម្ពផ្សាយដោយសាលាបារាំងចុងបូព៌ាប្រទេសថា ហ្វូណនមានកំពង់ផែធំសំខាន់មួយនៅ អូរ កែវ បារាំងហៅថា អុក អែវ ជាទីប្រជុំនៃអ្នកជំនួញមកពីគ្រប់ទិសទីនៃពិភពលោក។ កំពង់ផែនេះ មិនត្រឹមតែទទួលសំពៅមកពីប្រទេសចិន ម៉ាឡេស៊ី និងឥណ្ឌាប៉ុណ្ណោះទេ ក៏មានមកពីប្រទេសហូឡង់ផងដែរ។

កំពង់ផែអូរ កែវ ស្ថិតនៅខេត្តពាមបន្ទាយមាស កម្ពុជាក្រោម យួនបានប្តូរទៅជាខេត្តហា ទៀង ទៅជា កៀង យ៉ាង នៅជាប់ព្រំដែនខេត្តកំពត បច្ចុប្បន្នក្លាយជាកូនភ្នំតូចមួយមានរាងចតុកោណកែង មានទទឹង ១គីឡូម៉ែត្រកន្លះ បណ្តោយ ៣គីឡូម៉ែត្រ។ ស្ថិតនៅទិសអាគ្នេយ៍ជើងភ្នំបាថេ។

លោក Louis Malleret បានសរសេរទៀតថា អូរ កែវ មិនមែនត្រឹមតែបុរីសមុទ្រនោះទេ តែជារាជធានីដ៏ទំនើបរបស់ហ្វូណន ឬនគរភ្នំ ទៀតផង។ ដោយសារការរីកចំរើននេះហើយ ទើបព្រះមហាក្សត្រខ្មែរបានសាងរាជធានីនៅព្រៃត ឬព្រៃនគរ យួនបានប្តូរជា សៃហ្គន បច្ចុប្បន្នជាទីក្រុងហោជីមិញ។ បើតាមលោក Sylvestre ដែលបានសរសេរនៅក្នុងសៀវភៅរបស់លោកឈ្មោះ អាណាចក្រអណ្ណាម ថា ព្រះមហាក្សត្រខ្មែរទាំងឡាយបានសោយរាជ្យនៅរាជធានីព្រៃនគរប្រហែល ២៥៥ឆ្នាំ មុនគ្រឹស្តសករាជ។

ឆ្នាំ១៩២០ ក្រុមបុរាណវិទ្យាមួយក្រុមបានថតទិដ្ឋភាពទឹកដីកម្ពុជាក្រោមទាំងមូលពីលើអាកាស ហើយបានឃើញតំបន់ អូរ កែវ មានព្រៃកដីកជាច្រើន ហើយកន្លែងខ្លះមានសណ្ឋានជាទីក្រុងទៀតផង។ រហូតដល់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៤៤ លោក Louis Malleret បុរាណវិទូបារាំង បានធ្វើការសិក្សាស្រាវជ្រាវទៅលើសំណង់ចាស់ៗទាំងនោះឡើងវិញ ហើយបានកកាយជីករុករក ដើម្បីរកវត្ថុបុរាណទាំងឡាយនៅទីនោះ យកមកធ្វើការពិសោធន៍។

លោក Louis Malleret បានសរសេររៀបរាប់ថា អូរ កែវ ប្រហែលជាទីក្រុងវ៉េនីស (Venice) របស់ *ហ្វូណន* ដែលជាទីក្រុងដ៏ធំបំផុតនៅអាស៊ីនេះហើយ ព្រោះជាបុរីដ្ឋានមួយនៅជាប់មាត់ទឹក ដែលមានសង់ជាគេហដ្ឋានតំរៀបជាជួរដោយសម្ភារៈស្រាលៗទៅតាមការប្រែប្រួលនៃធាតុអាកាសធម្មជាតិ។ ដោយការខិតខំប្រឹងប្រែងស្រាវជ្រាវយ៉ាងសកម្ម ក្រុមអ្នកបុរាណវិទូ បានកាយរកឃើញគ្រឹះព្រះវិហារធ្វើអំពីថ្មនៅសេសសល់កប់យ៉ាងជ្រៅក្នុងស្រទាប់ដី។ រកឃើញឧបករណ៍ថ្មរំលីង គ្រឿងចានឆ្នាំងធ្វើពីដី គុជ ខ្សែក កងដៃធ្វើអំពីកែវ អំពីថ្មដ៏មានតម្លៃ រូបចម្លាក់សំណាវត្ថុធ្វើអំពីសំណប៉ាហាំង វត្ថុធ្វើអំពីដែក អំពីមាសប្រមាណ ១៣០០មុខ ទម្ងន់ ១១២០គីឡូក្រាម។

ដោយកំណាយឃើញជាក់ស្តែងបែបនេះ សារព័ត៌មានរបស់យួនឈ្មោះ Le Journal d'Extrême-Orient ចេញផ្សាយថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៦២ បានចុះផ្សាយនូវសេចក្តីថ្លែងការណ៍ជាផ្លូវការមួយរបស់អាជ្ញាធរយួននៅខេត្តពាមបន្ទាយមាស (យួនប្តូរទៅជា ហា តៀង ទៅជា កៀង យ៉ាង) ដោយបានវាយតម្លៃ និងទទួលស្គាល់យ៉ាងច្បាស់ថា អូរ កែវ ពិតជាទីក្រុងវ៉េនីស (Venice)។ នេះ បញ្ជាក់ឲ្យឃើញច្បាស់ថា យួនបានទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រ ជាទឹកដីខ្មែរយ៉ាងពិតប្រាកដ។

ចំណែកលោក Dauphin Meunier បានសរសេរសៀវភៅការងាររបស់ពួកឯកទេសស្រាវជ្រាវរកឃើញអូរ កែវ ថាផ្នែកកសិកម្មក៏មានការរីកចម្រើនខ្លាំងណាស់ដែរ។ ព្រះមហាក្សត្រខ្មែរទាំងឡាយនៃនគរហ្វូណន បានយកព្រះទ័យទុកដាក់យ៉ាងខ្លាំងចំពោះកសិកម្ម។ ព្រះអង្គបានត្រាស់បង្គាប់ឲ្យប្រជានុរាស្ត្រកសាង និងថែរក្សាអាងទឹក ជីកប្រឡាយបញ្ចូលទឹកសាបបានជាង ២០០គីឡូម៉ែត្រ។ ព្រះអង្គបានប្រែក្លាយទឹកដីហ្វូណនទៅជាទឹកដីមានជីវជាតិសម្រាប់កសិកម្ម។ ជាមួយគ្នានេះ លោកបេសកជនចិនបាននិទានរៀបរាប់ថា ព្រះមហាក្សត្រខ្មែរទាំងឡាយនៃនគរហ្វូណន មានការប៉ិនប្រសប់ខ្លាំងណាស់ក្នុងនយោបាយកសិកម្ម ព្រះអង្គបានប្រែក្លាយទឹកដីហ្វូណន ជាទឹកដីកសិកម្មដ៏ប្រណិត មានការរីកចម្រើនយ៉ាងក្រៃលែង។

ថ្មីៗនេះ លោក ង្វៀង មិញ សាង Nguyen Minh Sang ប្រធានមន្ទីរវប្បធម៌ខេត្តមាត់ជ្រូក (យួនប្តូរជា អាង យ៉ាង) នៃអាជ្ញាធរវៀតណាមកុម្មុយនិស្ត បច្ចុប្បន្ន បានទទួលស្គាល់ដោយគ្មានអល់អែកថា វប្បធម៌ អូរ កែវ ឬអុក អែវ គឺជាមរតកវប្បធម៌របស់ខ្មែរយ៉ាងពិតប្រាកដ ដែលមានតាំងពីសតវត្សរ៍ទី១ មកម្ល៉េះ។ លោក ង្វៀង មិញ សាង Nguyen Minh Sang បានបន្តទៀតថា កេរតំណែលនៃវប្បធម៌ខ្មែរនេះ ត្រូវបានរកឃើញនៅគ្រឹស្តសករាជ១៩៤២ ហើយបានចាប់ធ្វើការស្រាវជ្រាវនៅគ.ស១៩៤៤ រហូតដល់ ឆ្នាំ១៩៨៣ ។ នៅក្នុងការសិក្សាស្រាវជ្រាវគាស់កកាយនេះ បានរកឃើញវត្ថុបុរាណមួយចំនួន ដូចជាគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ ថ្មចម្លាក់ លិង្គព្រះឥសូ គ្រឿងអលង្ការ ឧបករណ៍តន្ត្រីយ៍ សម្លៀកបំពាក់ និងឥដ្ឋសម្រាប់ប្រើប្រាស់ជាសំណង់ផ្សេងៗជាដើម។ លោក ង្វៀង មិញសាង បានបញ្ជាក់ទៀតថា មរតកវប្បធម៌អូរ កែវ ដែលបានតម្កល់ទុកនៅសារមន្ទីរវប្បធម៌ខេត្តមាត់ជ្រូក Chau Doc មានជាង ១០.០០០មុខ ហើយត្រូវបានរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ទទួលស្គាល់ជាថ្នាក់ជាតិនៅឆ្នាំ១៩៨៧។

THE KHMER KAMPUCHEA KROM COMMUNITY

## អំពីប្រទេស ហ្វូណន និងអាណាចក្រភ្នំ

តាមការសិក្សាស្រាវជ្រាវរបស់យើងបានឲ្យឃើញថា ពាក្យហ្វូណន ឬ អាណាចក្រភ្នំ គឺជាពាក្យតែមួយសម្រាប់ហៅប្រទេសខ្មែរកាលពីសម័យដើម។ ក្រៅពីឈ្មោះ ហ្វូណន ឬអាណាចក្រភ្នំ ប្រជារាស្ត្រខ្មែរបានហៅម្យ៉ាងទៀតថា គោកធ្លក ឬ នគរគោកធ្លក។ ក្រុមអ្នកឯកទេសខាងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបានសរសេរថា នៅដើមគ្រិស្តសករាជ អាណាចក្រភ្នំ គឺជាប្រទេសមួយដ៏សំខាន់នៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ពាក្យហ្វូណន ត្រូវបានក្រុមអ្នកប្រវត្តិសាស្ត្រកត់ត្រាជាឈ្មោះនៃទឹកដីខ្មែរតាំងពីសម័យដើមនៃគ្រិស្តសករាជជារៀងរហូតមក។

លោក George Cœdès បានសរសេរក្នុងសៀវភៅរបស់លោកឈ្មោះ The Indianized States of Southeast Asia, A.D.1968, A.D.1975, first published in A.D.1948 as Les états Hindouisés d'Indochine et d'Indonésie ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៤ថា ពាក្យហ្វូណន ត្រូវនឹងពាក្យខ្មែរបូរាណថា វ្នំ ដែលសព្វថ្ងៃបានហៅក្លាយមកជាភ្នំ។ លោក George Cœdès បានបញ្ជាក់ថា ព្រះមហាក្សត្រកាលពីសម័យនោះគេហៅថា ស្តេចភ្នំ ពាក្យខ្មែរបូរាណហៅថា កុរុងវ្នំ ត្រូវនឹងពាក្យសំស្ក្រឹតថា បវិតតភូបាល ឬ សៃលរាជ។ លោក George Cœdès បានសរសេរបន្តទៀតថា ឯកសារចិនបាននិយាយយ៉ាងច្បាស់ថា ព្រះមហាក្សត្រដែលសោយរាជ្យនៅអាណាចក្រភ្នំ មានឋានន្តរនាមថា គូឡុង គឺក្រុង ដូចសព្វថ្ងៃមានន័យថា ស្តេចសោយរាជ្យ ។ ដូច្នេះហ្វូណន ចិនហៅតាមឋានន្តរនាមរបស់ព្រះមហាក្សត្រអាណាចក្រភ្នំ គឺកុរុងភ្នំ។

សរុបសេចក្តីមក អ្នកសិក្សាស្រាវជ្រាវ និងប្រវត្តិវិទូទាំងឡាយបានយល់ស្របគ្នាថា ហ្វូណន ឬនគរភ្នំ ស្ថិតនៅត្រង់វាលទំនាបនៃទន្លេមេគង្គ គឺកម្ពុជាក្រោមនេះឯង។

## ការបង្រួបបង្រួម ហ្វូណន និងចេនឡា

តាមឯកសារប្រវត្តិសាស្ត្រនៃពង្សាវតារខ្មែរបានសរសេរថា ព្រះមហាក្សត្រខ្មែរព្រះនាម ព្រះនាងលីវយី ឬសោមា ជាបឋមក្សត្រខ្មែរបានឡើងសោយរាជ្យគ្រប់គ្រងទឹកដីកម្ពុជាក្រោមដំបូងបង្អស់។ ទឹកដីកម្ពុជាក្រោមកាលពីសម័យនោះមានឈ្មោះថា នគរហ្វូណន ។ ការសោយរាជ្យសម្បត្តិនៃរាជវង្សខ្មែរបានបន្តនៅលើទឹកដីកម្ពុជាក្រោមរហូតដល់ឆ្នាំ៥៥០នៃគ្រិស្តសករាជ ទើបមានការបង្រួបបង្រួមដ៏ធំមួយនៃរាជាណាចក្រហ្វូណន និងចេនឡាលើ (ចេនឡាដីគោក) ទៅជាព្រះរាជាណាចក្រកម្ពុជា។ ស្ថាបនិកដំផ្តើមនៃការបង្រួបបង្រួមបង្កើតបានទៅជាព្រះរាជាណាចក្រកម្ពុជា រហូតបច្ចុប្បន្ន ដែលអ្នកប្រវត្តិសាស្ត្រកំពូលៗបានទទួលស្គាល់នោះ គឺព្រះបាទភវវរ្ម័ន ។

ចាប់តាំងពីការកកើតទឹកដីនៃរាជាណាចក្រខ្មែរ ទាំងនគរហ្វូណនក្តី ចេនឡាក្តី រហូតដល់មានការរួបរួមបង្កើតបានទៅជាព្រះរាជាណាចក្រកម្ពុជាក្តី ពុំដែលឃើញមានវត្តមានជនជាតិយួននៅលើទឹកដីខ្មែរទេ។ រហូតដល់ឆ្នាំ១៦២៣ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ ទើបឃើញវត្តមានជនជាតិយួនដំបូងបង្អស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គឺតាមរយៈរាជាភិសេកព្រះបាទជ័យជេដ្ឋាទី២ ជាមួយបុត្រីនៃរាជវង្សយួន ។

មានន័យថា មុននឹងមានការបង្រួបបង្រួមប្រទេសទាំងពីរ ហ្វូណន និងចេនឡា ព្រះរាជវង្សនៃបឋមក្សត្រខ្មែរបានសោយរាជ្យនៅនគរហ្វូណន ដំបូងគេរហូតដល់មានការបង្រួបបង្រួមទៅជាព្រះរាជាណាចក្រកម្ពុជា ក្នុងគ.ស៥៥០។ ក្នុងនោះមាន ព្រះនាង លីវ យី ឬសោមា, ព្រះបាទហ៊ុន ទៀន, [illegible] ហ៊ ហ្វាន់ ហឿន, ព្រះបាទហ្វាន់ ហ្វាន, ព្រះបាទហ្វាន់ ម៉ាន់, ព្រះបាទហ្វាន់ចន្ទ, ព្រះបាទហ្វាន់ [illegible]

THE KHMER KAMPUCHEA KROM COMMUNITY

ព្រះបាទ ជូ ចិន្តាន, ព្រះបាទសុទ្ធវ៉ន្ម៉ែ, ព្រះបាទ ស្រីសត្តវ៉ន្ម៉ែ, ព្រះបាទកោណ្ឌញ្ញវ៉ន្ម៉ែ, ព្រះបាទរុទ្រវ៉ន្ម៉ែ និងព្រះបាទភវវ៉ន្ម៉ែ (ព្រះមហាក្សត្របង្រួបបង្រួមប្រទេសមុនគេ) ។

## ភស្តុតាងសក្ការៈបូជានៅកម្ពុជាក្រោម ( ហ្វូណន )

ដោយពុំមានលទ្ធភាព និងកង្វះឯកសារ យើងសូមលើកយកតែកន្លែងសំខាន់ៗខ្លះមកបញ្ជាក់ជាភស្តុតាងតែប៉ុណ្ណោះ។

នៅខាងត្បូងភ្នំខ្លោ និងភ្នំបាថេ ឃើញមានចារឹកថ្មបីជុំ ដែលសុទ្ធតែចែងអំពីប្រវត្តិរបស់ស្តេច ជាហេតុធ្វើឲ្យយើងសន្និដ្ឋានបានថា ជាកន្លែងព្រះមហាក្សត្រខ្មែរជំនាន់ដើមគង់នៅ។

នៅភ្នំសំ (នួយ សំ) យើងឃើញព្រះទេវរូបសិរៈមួយព្រះអង្គ និងព្រះសុរង្គស្តេចគំលង់ដែលយើងធ្លាប់ប្រទះឃើញនៅអង្គរវត្តមួយព្រះអង្គផងដែរ។

នៅព្រែកឫស្សី (គីង ថើ) យើងឃើញរូបព្រះសិរៈដ៏ល្អប្រណិតមួយព្រះអង្គធ្វើអំពីទងដែង។

នៅកោ ឡាញ់ យើងឃើញព្រះពុទ្ធរូបមួយព្រះអង្គមុនសម័យអង្គរធ្វើអំពីឈើ។

នៅខាងក្រោមទន្លេបាសាក់ នៅពីខាងជើងទីរួមខេត្តឃ្លាំង ចម្ងាយប្រហែល ១០គីឡូម៉ែត្រ យើងឃើញមានកន្លែងតាំងបូរាណវត្ថុជាង ២០កន្លែង និងមានរូបចម្លាក់មួយមិនសម័យអង្គរទៀតផង។

នៅសារមន្ទីរទីក្រុងព្រៃនគរ យើងឃើញមានវត្ថុបូរាណយ៉ាងច្រើន ទាំងមុនសម័យអង្គរនិងក្រោយសម័យអង្គរ។

## ភស្តុតាងនៃប្រាសាទខ្មែរនៅកម្ពុជាក្រោម

លោក Etienne Edmond Lunet De Lajonquiere បានសរសេរនៅក្នុងសៀវភៅរបស់លោក ភាគទី៣ ទំព័រ ៥៦៨ ទៅ ៥៨១ថា ដោយហេតុថា ទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ ដូច្នេះសម្បូរណ៍ទៅ ដោយប្រាសាទនិងសិល្បៈប្រកបដោយទេពកោសល្យដ៏ខ្ពង់ខ្ពស់ដូចគ្នានិងសិល្បៈនៃប្រាសាទទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជានេះដែរ។ ប្រាសាទទាំងនោះ គឺ៖

ប៉មចុតម៉ាត់ឬបាបូ(Tour de Chot Mat ou Ba Bo)ប្រាសាទនេះសង់អំពីឥដ្ឋសម័យដើម មានពីរជាន់រាងដូចជាប៉ម ឬសើន។ ក្បាច់រចនាមិនសូវសម្បូរណ៍ទេ គឺគ្រាន់តែជាប៉មមួយ ដែលមានសណ្ឋានដូចប្រាសាទតូចៗខ្លះនៅអង្គរធំ។

នៅខេត្តពាងជំរី (តី នីញ) នៅខេត្តពាងជំរីមានភ្នំមួយហៅថា ភ្នំជើងបាដែង បច្ចុប្បន្នយួនប្តូរទៅជាភ្នំបានែង។ នៅលើភ្នំនេះមានវត្តព្រះពុទ្ធសាសនាខ្មែរមួយមានអាយុរាប់ពាន់ឆ្នាំ គឺតាំងពីសម័យមហា អំណាចខម ត្រួតត្រាដែនដីសុវណ្ណភូមិម្លេះ។ នៅទីនោះ យើងប្រទះឃើញលិង្គព្រះឥសូរធ្វើពីថ្មសម្លៀងមួយយ៉ាងធំ មានបដិមាទេពធីតាមួយព្រះអង្គ ដើមដៃទេវរូបមួយកំណាត់ មុខលិង្គព្រះឥសូរមួយកំណាត់បដិមាព្រះបាទអាសោករាជមួយ ព្រះបដិមាព្រះសិរៈមួយព្រះអង្គ ដែលមានបល្ល័ង្កទ្រូវរូបមនុស្សប្រុសមួយ បដិមាព្រះវិស្ណុតូចមួយព្រះអង្គ ។ល។

នៅបុង បឺន (Bung Binh) នៅច្រាំងម្ខាងនៃព្រែកព្រៃនគរ យើងឃើញមានសំណល់ប្រាសាទមួយទើបបែកបាក់។

សិលាចារឹកនៅភូ ហ៊ុយ នៅភូ ហ៊ុយ មានវត្ថុដ៏សំខាន់បំផុត ដែលបានបញ្ជាក់អំពីសិល្បៈ និងអារ្យធម៌ខ្មែរនៅទីនោះ គឺមានសិលាចារឹកមួយផ្ទាំង ដែលសរសេរជាភាសាសំស្ក្រឹតពីរបន្ទាត់ និងជាភា[illegible] ១៤បន្ទាត់។

នៅទៀ អ៊ី ហូ Tea I Ho មានប្រាសាទមួយនៅសល់នៅឡើយ។ ប្រាសាទនេះសាងអំពី[illegible]ហើយ

មានទេវរូបព្រះវិស្ណុមួយព្រះអង្គតាំងនៅក្នុងប្រាសាទផងដែរ។

នៅភ្នំបាថេ មានបុរាណវត្ថុជាច្រើន ដែលជាសក្ខីកម្មបញ្ជាក់អំពីសល្បៈរបស់ខ្មែរឥតប្រកែកបាន និងមានឃើញសំណល់ប្រាសាទមួយ និងសិលាចារឹកពីរផង ។ល។

## អស្តុតាងខ្មែរលើអត្ថបទជាឯកសារ

តាមការស្រាវជ្រាវឯកសារទាំងឡាយ ទាំងជាភាសាខ្មែរក្ដី ភាសាវៀតណាមក្ដី ភាសាបារាំងក្ដី សុទ្ធសឹងឃើញថា ទឹកដីកម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរ មិនអាចប្រកែកបាន។ វត្តមានយួននៅលើទឹកដីខ្មែរដំបូងបង្អស់ គឺនៅក្នុងឆ្នាំ១៦១៨ តាមរយៈព្រះរាជអគ្គមហេសីព្រះបាទជ័យជេដ្ឋាទី២ ឈ្មោះគូជីន (ព្រះ នាងទី៩) ជាបុត្រីស្ដេចយួនឈ្មោះ ង្វៀង សាយ វៀង។នៅឆ្នាំ១៦២៣ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ដដែល ព្រះចៅក្រុងវេ ង្វៀង សាយ វៀង បានបញ្ជូនគណៈប្រតិភូមួយក្រុមមកគាល់ព្រះចៅក្រុងកម្ពុជានៅ រាជធានីឧត្តុង្គ។ ក្រៅពីការលើកសរសើរបញ្ចើចបញ្ចើព្រះបាទជ័យជេដ្ឋាទី២ គណៈប្រតិភូយួនក៏បានស្នើ សុំកោះក្របី (ព្រៃនគរ) ដើម្បីហ្វឹកហាត់កងទ័ពច្បាំងជាមួយយចិន ឯកសារខ្លះថា ដើម្បីធ្វើគ្រឹះស្ថានជំនួញក្នុងរយៈពេល ៥ឆ្នាំ។ (សៀវភៅ "អំពីព្រៃនគរ" របស់លោក Jean Bouchot ទំព័រទី១២)។

ឆ្លើយតបនឹងសំណើរបស់ព្រះចៅក្រុងវេ ព្រះបាទជ័យជេដ្ឋាទី២ បានយល់ព្រមអនុញ្ញាតឲ្យព្រះចៅក្រុងវេ ខ្ចីដីព្រៃនគរចំនួន ៥ឆ្នាំ។

លោក Petrus Jean Baptiste និង Truong-Vinh-Ky បានសរសេរក្នុងសៀវភៅរបស់លោកឈ្មោះ មេរៀនប្រវត្តិសាស្ត្រយួន ភាគ២ ក្បាលទី៥ ទំព័រ ១៣៥ - ១៣៦ (Cours D'Histoire Annamite V1-2: A L'usage Des Ecoles De La Basse-Cochinchine (1875) (French Edition) Vol 11 Torme 5, pages 153 - 136)ថា នៅមុនឆ្នាំ១៦៥៨ មានពួកមនុស្សជាច្រើនបានចូលមកកម្ពុជាក្រោមយ៉ាងអនាធិបតេយ្យ មានពួកចោរប្លន់ មានពួកទាហានរត់ចោលជួរ(ពួកយួន) មកនៅលាយឡំជាមួយនិងប្រជារាស្ត្រខ្មែរតាមស្រុកស្រែចំការ រួចហើយតាំងទីលំនៅទីនោះតែម្ដង។ ជាពិសេសពួកយួនទាំងនោះក្ដាប់យកផ្នែកកសិកម្ម គឺនៅ ម៉ូ សយ ក្នុងខេត្តព្រះសួគ៌ា (បារៀ) ខេត្តដូន ណៃ (ដុង ណាយ) និងខេត្តកំពង់ស្រកាត្រី (បៀងហ្វា)។ ដូច្នេះហើយទឹកដីខ្មែរកម្ពុជាក្រោម បានធ្លាក់ទៅកណ្ដាប់ដៃពួកយួនបន្តិចម្ដងៗចាប់ពីពេលនោះរហូតមក។

លោក Jean Bouchot ក្នុងសៀវភៅរបស់លោកអំពីព្រៃនគរ ត្រង់ទំព័រ ១៦ និងលោក Muraត្រង់ទំព័រ ៦៥ បានសរសេរថា នៅឆ្នាំ១៦៧៥ រដ្ឋាភិបាលអាណ្ណាម បានប្រគល់មកឲ្យព្រះរាជាណាចក្រកម្ពុជា វិញនូវខេត្តមួយចំនួន ដែលខ្លួនបានដណ្ដើមយក ដូចជាខេត្តព្រះសួគ៌ា, ខេត្តកំពង់ស្រកាត្រី និងខេត្តនានា មួយចំនួនទៀត ដែលខ្លួនបានរុករានទន្ទ្រានយកក្នុងពេលដែលខ្មែរមានវិបត្តិផ្ទៃក្នុង។

នៅក្នុងសៀវភៅ យ៉ាឌីន ទុងជី (Gia Dinh thong chi) របស់លោក ត្រឹង ហ្វាយនឹក Trịnh Hoài Đức (1765 - 1825) ដែលជាប្រវត្តិវិទូដ៏ល្បីរបស់យួន ក្នុងឆ្នាំ១៨៣០បានសរសេរទទួលស្គាល់យ៉ាងច្បាស់ថា ទឹកដីទាំងអស់នៃខេត្តម៉ូ សយ (យួនហៅថា Mo Xoai) និងខេត្តដូនណៃ (យួនហៅថា Dong Nai) ត្រូវបាន ពួកអណ្ណាមអាពសែចូលកាន់កាប់។ ហើយពួកអណ្ណាមអាពសែទាំងនោះ បានទាំងចូលទៅរស់នៅលាយ ឡំជាមួយប្រជារាស្ត្រខ្មែរទៀតផង។

លោក ត្រឹង ហ្វាយនឹក បានគូសបញ្ជាក់ទៀតថា ពួកអណ្ណាមទាំងនោះក្ដោបក្ដាប់ផ្នែកកសិកម្ម។ ខ្មែរពេលនោះខ្លាចសន្តិវង្សអណ្ណាមជាទីបំផុត មិនហ៊ានងើបតវ៉ាឬប្រឆាំងពួកអណ្ណាមដែលធ្វើអាណានិគមលើទឹកដីរបស់ខ្លួនឡើយ។

សហគមន៍ខ្មែរកម្ពុជាក្រោម
THE KHMER KAMPUCHEA KROM COMMUNITY

ព្រះករុណាព្រះមហាវីរក្សត្រ ព្រះបាទអង្គ ឌួង បានផ្ញើព្រះរាជសារជាច្រើនច្បាប់ ដើម្បីទាក់ទងព្រះចៅណាប៉ូឡេអុងទី៣ Napoleon III នៃប្រទេសបារាំងឲ្យជួយអន្តរាគមន៍យកកម្ពុជាក្រោមមកវិញ។ ក្នុងនោះឃើញមានព្រះរាជសារមួយច្បាប់នៅខែវិច្ឆិកា ឆ្នាំ១៨៥៥ បានថ្វាយព្រះចៅអធិរាជ ណាប៉ូឡេអុងទី៣ តាមរយៈឯកអគ្គរាជទូតបារាំងនៅសិង្ហបុរី Singapore គឺលោក Louis Charles de Montigny ដើម្បីទាក់ទង ជាមិត្តភាព និងសហប្រតិបត្តិការ និងស្នើសុំជំនួយពីស្តេចណាប៉ូឡេអុងទី៣ ក្នុងកិច្ចការពារព្រះរាជាណាចក្ររបស់ព្រះអង្គ។ ជាពិសេស ជួយវាយយកកម្ពុជាក្រោមមកវិញ។ ស្តេចណាប៉ូឡេអុង មិន ឆ្លើយតបនឹង រាជសារនេះទេ។

នៅឆ្នាំ១៨៥៦ ព្រះអង្គបានថ្វាយស្តេចណាប៉ូឡេអុងមួយច្បាប់ទៀត ។ ព្រះរាជសារបានបញ្ជាក់អំពីសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានៅលើទឹកដីកម្ពុជាក្រោម ហើយសុំកុំឲ្យស្តេចណាប៉ូឡេអុងទទួលយកទឹកដីនៃផ្នែកណាមួយនៅកម្ពុជាក្រោម ដែលស្តេចអណ្ណាមថ្វាយឲ្យសោះ ព្រោះជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាទេ។ ជាមួយនោះ ព្រះអង្គបានថ្វាយនូវជំរឹតការពារ ៤ក្បាល, ស្នែងរមាស ២,ថ្នាំគូតំនូវពណ៌លឿងចំនួន ៥០Piculs, ស្ករ ៥Piculs, ម្រេច ៤Piculs ដល់ស្តេចណាប៉ូឡេអុង ផងដែរ។

នៅឆ្នាំ១៨៥៧ ព្រះករុណាព្រះបាទអង្គ ឌួង បានស្នើសុំជាថ្មីទៀត តាមរយៈ Monseigneur Jean-Claude Miche សុំឲ្យព្រះចៅណាប៉ូឡេអុងទី៣ បញ្ជូនទ័ពបារាំងមកវាយយកទឹកដីព្រៃនគរឲ្យខ្មែរ ដោយព្រះអង្គសន្យាថា នៅពេលដែលវាយជះឈ្នះបាន ព្រះអង្គនឹងប្រទានប្រាក់ចំនួន ៥០០ពាន់ជាសគុណ។ ចំណែកព្រះអង្គរៀបចំទ័ពវាយយកខេត្តទ្រាំង (ខេត្តឃ្លាំង) ព្រះត្រពាំង,ក្រមួនស,មាត់ជ្រូក(ពង្សាវតាគំកល់នៅព្រះបរមរាជវាំង ទំព័រ ៧៥៥ Annales depose au Palais Royal, page 755)។

នៅពេលសង្គ្រាមលោកលើកទី២ ជប៉ុនបានកាន់កាប់កម្ពុជាក្រោមទាំងមូល។ ពេលនោះព្រះ ករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានផ្ញើព្រះរាជសារមួយច្បាប់ជូនអធិរាជជប៉ុន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ បញ្ជាក់ជូនអធិរាជជប៉ុនអំពីសិទ្ធិរបស់កម្ពុជានៅលើទឹកដីកម្ពុជាក្រោម។

នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៤៨ ព្រះករុណា នរោត្តម សីហនុ បានផ្ញើព្រះរាជសារ ១ច្បាប់ ជូនស្នងការជាន់ខ្ពស់បារាំង ក្នុងការប្រឆាំងជំទាស់មិនឲ្យបារាំងទទួលស្គាល់សំណើរបស់ស្តេច បៅ ដាយ ក្នុងការស្នើឲ្យមានការរួបរួម Ky ទាំង៣គឺ ត្រុង គី, បាក់ គី និងណាម គី (Trung Ky, Bac Ky, Nam Ky)។ មានន័យថា យួនកណ្តាល, យួនខាងជើង និងយួនខាងត្បូង ជាប្រទេសយួនតែមួយ។ តែក្នុងព្រះរាជសាររបស់ព្រះអង្គបានប្រឆាំងដាច់ខាត ដោយបានលើកឡើងប្រាប់បារាំងថា យួនពុំមានទឹកដីឯណាយកទៅរួបរួមទេ គឺយកទឹកដីខ្មែរ ដែលយួនហៅថា ណាម គី ទៅរួបរួមតែប៉ុណ្ណោះ។

ក្នុងបទអន្តរាគមន៍របស់សម្តេចបវរសេដ្ឋា សឺន សាន ក្នុងឋានៈតំណាងប្រទេសកម្ពុជា ថ្លែងចំពោះមុខក្រុមប្រឹក្សាជាន់ខ្ពស់នៃសហភាពបារាំង ក្នុងសម័យប្រជុំថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ១៩៥១ ដោយបានរំលឹកអំពីលក្ខខ័ណ្ឌទាំងឡាយដែល ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានធ្វើឡើងជាសាធារណៈក្នុងឋានៈជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលរបស់ព្រះអង្គអំពីសិទ្ធិស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជានៅលើទឹកដីកម្ពុជាក្រោម ។

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បាននៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី១២ ឆ្នាំ១៩៥៧ លើកទី១៥ ឆ្នាំ១៩៦០លើកទី១៦ ឆ្នាំ១៩៦១។ និក្ខេបបទរបស់ប្រទេសកម្ពុជាស្តីអំពីទឹកដីខ្មែរ (កម្ពុជាក្រោម) នៅវៀតណាមខាងត្បូង បានប្រគល់ជូនគណៈប្រតិភូបណ្តាប្រទេសជា សមាជិកទាំងអស់ (ក្នុងមហាសន្និបាតលើកទី១២)។ ថ្លែងទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ [illegible] ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៦១ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានគូសបញ្ជាក់ [illegible]មហា



THE KHMER ... A KROM COMMUNITY

សន្និបាតថា កូសាំងស៊ីន(កម្ពុជាក្រោម)បច្ចុប្បន្នវៀតណាមខាងត្បូង ជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ដែលវៀតណាមបានដណ្តើមយកកាន់កាប់នៅពេលដែលបារាំងបានមកដល់នៅពាក់ កណ្តាលសតវត្សរ៍ទី១៩។

## ភស្តុតាងសំអាងលើផែនទី

***១-ផែនទីឥណ្ឌូចិននៅសតវត្សទី៧ និង ទី៨***

តាមផែនទីទាំងនេះយើងបានមើលឃើញយ៉ាងច្បាស់លាស់បំផុតអំពីទីតាំងរបស់ប្រទេសកម្ពុជា ដោយនិយាយប្រៀបធៀបទៅនឹងប្រទេសជិតខាងរបស់ខ្លួន គឺប្រទេសសៀម ប្រទេសលាវប្រទេសអណ្ណាម និងនគរចម្ប៉ា ។ នៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជា" ត្រង់ទំព័រទី ១១ (Histoire du Cambodge, Claudius Madrolle, A.D.1870 - A.D.1949) លោក ម៉ាដ្រូល បានសរសេរថា ផ្នែកដែនដីរួមនៅក្នុងព្រំដែន ព្រះរាជាណាចក្រកម្ពុជានេះហើយគឺជាផ្នែកទាំងស្រុងមួយនៃបូរណភាពទឹកដីរបស់ខ្មែរ(គឺជារបស់ខ្មែរទាំងស្រុង)។

***២-ផែនទីឥណ្ឌូចិន ឥណ្ឌាខាងកើត***

គូរនៅឆ្នាំ១៥៩៣ ដកស្រង់ពីសៀវភៅផែនទីភូមិសាស្ត្រUrtelina(ជំនួយស្មារតីឯកសាររបស់ក្រសួងការបរទេសនៃប្រទេសកម្ពុជា ស្តីអំពី ជនជាតិភាគតិចកម្ពុជា) ដែលគេបានគូរជា ថ្មីឥតមានកែប្រែ គំនូស (Traces) របស់ផែនទីគូរនោសតវត្សទី៧នោះ កូសាំងស៊ីនក្រោម ដែលកើតឡើងដោយដីដុះនិង ល្បប់ទន្លេមេគង្គជាទីតាំងបន្តនៃព្រះរាជាណាចក្រកម្ពុជានៅលើដីដុះធម្មជាតិ (Continuation Geologiqueឬ Geological Continuation) នៃប្រទេសគោកធ្លក ។

***៣-ផែនទីឥណ្ឌូចិនគូរនៅឆ្នាំ១៦៣៨***

ចំនួន៣០ឆ្នាំក្រោយមកទៀត គេបានគូរផែនទីមួយទៀត ដែលបានបង្ហាញយ៉ាងច្បាស់ថា "កូសាំងស៊ីន បច្ចុប្បន្នដែលជាដែនដីប៉ែកសមុទ្ររបស់កម្ពុជា នៅតែជាផែនដីទាំងមូលរួមក្នុងប្រទេសកម្ពុជា លាតសន្ធឹងតែម្នាក់ឯងគត់ រហូតដល់សមុទ្រ ជាព្រំដែនខាងត្បូងនិងអាគ្នេយ៍របស់ប្រទេសនេះ" ។

***៤-ផែនទីមហាអាស៊ីបូព៌ា***

ផែនទីមហាអាស៊ីបូព៌ា (ដែលសម្គាល់តំបន់សមុទ្រប៉ែកខាងត្បូង) គូរនៅក្នុងសម័យបារាំងរុករានអាស៊ី បានដាក់ព្រំដែនយ៉ាងច្បាស់លាស់បំផុត ។ ផែនទីនេះបានទាំងបង្ហាញយ៉ាងច្បាស់ពីប្រទេសកម្ពុជា ដែលលាតសន្ធឹងចាប់ពីព្រំប្រទល់នៃប្រទេសលាវរហូតដល់សមុទ្រ (តាមខ្សែទន្លេមេគង្គ) ដោយក្រសោបកម្ពុជាក្រោមទាំងស្រុងមួយរបស់ព្រះរាជាណាចក្រខ្មែរ ។

***៥-ផែនទីឥណ្ឌូចិនរបស់លោក រ៉ូបែរ គូរក្នុងឆ្នាំ១៧១៧***

ផែនទីមួយទៀត ដែលគូរដោយលោក រ៉ូបែរ (Robert) ក្នុងឆ្នាំ១៧១៧ នៅក្នុងសៀវភៅ "ឥណ្ឌូចិន (Indochine) ទំព័រ ១១៧ ក្បាលទី១ បានផ្តល់ឯកសារថ្មីមួយទៀតថា កម្ពុជាក្រោមជាដែនដីរបស់ប្រទេសកម្ពុជា ។

***៦-ផែនទីរបស់លោក ឌៀវីល Durville ឆ្នាំ១៧៥៥***

ពេលខាងក្រោយបន្តិចមក គឺមុនសន្ធិសញ្ញាក្រុងវែរសៃ Versailles ឆ្នាំ១៧៨៧ ដែលចុះហត្ថលេខារវាងលោក អេវ៉េក ដាដ្រង់ (Eveque d'Adran) ជាតំណាងប្រទេសអណ្ណាមនិងប្រទេសបារាំង ហើយដែលតាមសន្ធិសញ្ញានេះ លោក អេវ៉េក ដាដ្រង់ បាននាំទាំងហានបារាំងមួយក្រុមចូលមកវាយយកកម្ពុជាក្រោម ជាទឹកដីទាំងស្រុងរបស់ប្រទេសកម្ពុជា (សៀវភៅឥណ្ឌូចិន...ក្បាលទី១ ទំព័រទី ១៣៥ (L'Indochine Tome page 135) ។ល។

THE KHMER KAMPUCHEA KROM COMMUNITY

## ការរៀបចំរដ្ឋបាលគ្រប់គ្រងដែនដីកម្ពុជារបស់ព្រះមហាក្សត្រខ្មែរ

ព្រះបាទអង្គចន្ទទី១ បានរៀបចំឡើងវិញនូវរដ្ឋបាលគ្រប់គ្រងដែនដីកម្ពុជាក្រោម ដូចខាងក្រោម៖

នៅឆ្នាំ១៥២៨ ព្រះបាទអង្គចន្ទទី១ បានតែងតាំងពញ្ញាទែនឲ្យធ្វើជាចៅហ្វាយស្រុកបាសាក់ ដែលមានងារជា "ពញ្ញាអាធិកវង្សទែន " ។ ចៅហ្វាយស្រុកបាសាក់បានទទួលមរណភាពនៅឆ្នាំ១៥៥១ នៅក្នុងអាយុ ៧៣ឆ្នាំ។ ព្រះអង្គចន្ទ បានតែងតាំងពញ្ញាតាត ឲ្យបន្តវេនពីពញ្ញាទែន និងបានទទួលងារជាស្និទ្ធ ភូបាលតាត។ នៅក្នុងពេលនោះ ចៅហ្វាយខេត្តថ្មីៗបានសាងសង់នូវបន្ទាយទាំងឡាយ និងបានរៀបចំស្រុកបាសាក់ឡើងវិញ និងខេត្តទាំងអស់នៅកម្ពុជាក្រោម ។

នៅក្នុងស្រុកទ្រាំង ពញ្ញាតាត បានកសាងបន្ទាយមួយដូចបន្ទាយលង្វែក ដោយមានស្នាមភ្លោះនិងជញ្ជាំងធ្វើអំពីឫស្សី ។ ក្រោយពីមានទឹកជំនន់មួយមកស្និទ្ធភូបាលតាត បានបញ្ជាដល់ទាហានរបស់លោកឲ្យកសាងនូវជង្រុកស្រូវមួយនៅក្នុងទីក្រុងនៃស្រុកទ្រាំង ដើម្បីផ្ទុកស្រូវសម្រាប់អ្នកស្រុកទទួលទាន ក្នុងករណីដែលមានការរាំងស្ងួត ឬគ្រោះទុរ្ភិក្ស " ។ គឺចាប់ពីសម័យនោះមក អ្នកស្រុកបានហៅស្រុកទ្រាំងថា ជាស្រុកឃ្លាំងរហូតសព្វថ្ងៃ ។

នៅឆ្នាំ១៥៣៣ ស្និទ្ធភូបាលតាត បានបង្កើត "វត្តឃ្លាំង" ជាកន្លែងដែលគាត់បានរក្សាទុកនូវអ្វីទាំងអស់ ដែលគាត់សរសេរ ឬកត់ត្រាទុកអំពីសមិទ្ធិផលនានារបស់គាត់ ដែលរួមមាន

- ការកែប្រែស្រុកទ្រាំងទៅជាស្រុកឃ្លាំង
- ការបែងចែកស្រុកឃ្លាំង (កម្ពុជាក្រោម) ទៅជា ៥ខេត្ត ។
- ការរៀបចំកងទ័ពជើងគោក និងកងទ័ពជើងទឹក ។
- ការកំណត់បញ្ជារដ្ឋបាល និងគ្រឿងសព្វាវុធរបស់ទាហាន ។
- ទំនៀមទម្លាប់នៃការចូលឆ្នាំខ្មែរ
- ពិធីច្រត់ព្រះនង្គ័លសម្រាប់ដំណាំនៅក្នុងរដូវក្តៅ
- ល្បែងរបស់អ្នកចម្បាំង
- ពិធីបុណ្យអុំទូក

ស្និទ្ធភូបាលតាត បានបែងចែកស្រុកឃ្លាំង (កម្ពុជាក្រោម) ទៅជា ៥ខេត្ត គឺ

១-នៅកណ្តាល ជាខេត្តឃ្លាំង ជាមួយនឹងទីក្រុងនៃស្រុកទ្រាំង ឬឃ្លាំង ធ្វើជាទីរួមខេត្ត ។

២-ខេត្តព្រះត្រពាំង ដោយមានចៅហ្វាយស្រុកម្នាក់បានទទួលងារជា "មន្ត្រីសេនា បូរក្សទេស" ។

៣-ខេត្តពលលាវ ដោយមានចៅហ្វាយស្រុកម្នាក់មានងារជា "មន្ត្រីអាធិកសេនា" ។

៤-ខេត្តក្រមួន ស ដោយមានចៅហ្វាយស្រុកម្នាក់មានការងារជា "មន្ត្រីពិជិតសេនា" ។

៥-ខេត្តបាក់ប្រៃ ដោយមានចៅហ្វាយស្រុកម្នាក់មានងារជា "មន្ត្រីសេនាពជ័យសង្គ្រាម"។

ស្និទ្ធភូបាលបានទទួលមរណភាពនៅក្នុងអាយុ ៩៨ឆ្នាំ ។

កូនប្រុសរបស់លោកឈ្មោះ ឧកញ៉ា អាធិកវង្សា ឡុង បានបន្តវេនពីលោក ការបន្តវេនបានធ្វើពីឪពុកមកកូនដោយមានការយល់ព្រមពីព្រះមហាក្សត្រ ។

ឆ្នាំ១៥៥៦ នៅក្រោមរជ្ជកាលរបស់ព្រះបរមឥន្ទ្រារាជ (គ.ស.១៥៥៦ - គ.ស.១៥៦៧) ឡុង ជាកូនប្រុសរបស់ស្និទ្ធភូបាលតាត ត្រូវបានតែងតាំងជាចៅហ្វាយខេត្ត ឬអនុក្សត្រ នៅកម្ពុជាក្រោម [illegible] ទួលងារជា "ឧកញ៉ា អាធិកវង្សា ឡុង"។ ងាររបស់ចៅហ្វាយខេត្តកម្ពុជាក្រោមនេះ បាន ស្ថិតនៅរហូតដល់អ្នកបន្តវេនផ្សេងៗទៀតរបស់ឧកញ៉ា ឡុង ដោយរាប់តាំងពីសម័យនោះមក ។

THE KHMER KAMPUCHEA KROM COMMUNITY

លោកឧកញ៉ា ឡុង បានទទួលមរណភាពនៅក្នុងអាយុ ៨៩ឆ្នាំ នៅក្រោមរជ្ជកាលរបស់ព្រះបាទជ័យជេដ្ឋាទី២ (គ.ស.១៦១៨) លោកពុំមានកូនប្រុសបន្តវេនទេ ។

លោក ម៉ឺន ជ័យ ជាអ្នកបន្តវេន។ ម៉ឺន ជ័យ ត្រូវបានតែងតាំងជាចៅហ្វាយស្រុកបាសាក់ក្រោមងារជាឧកញ៉ា ទេសវង្សា តែងតាំងដោយព្រះបាទជ័យជេដ្ឋាទី២ ដើម្បីជំនួសឧកញ៉ា ឡុង ។

ឧកញ៉ា ទេសវង្សា ម៉ឺន ជ័យ បានទទួលមរណភាពនៅក្នុងជន្មាយុ ៨៣ឆ្នាំ នៅក្រោមរជ្ជកាលរបស់ព្រះអង្គចន្ទ ម៉ឺន ជ័យ បានតែងតាំងប្អូនប្រុសរបស់ខ្លួន ចៅពញ្ញាពេជ្រ ធ្វើជាចៅហ្វាយខេត្តបាសាក់នៅក្នុងឆ្នាំ១៦៥៥ ។ ចៅពញ្ញាពេជ្រ បានរស់នៅខ្វែងឡាច់ក្នុងខេត្តពលលាវ។ លោកបានទទួលមរណភាព នៅក្នុងជន្មាយុ ៧៥ឆ្នាំ ។

ចៅពញ្ញា មៅ បានបន្តវេនពីឪពុករបស់ខ្លួន ចៅពញ្ញាពេជ្រ នៅក្រោមរជ្ជកាលព្រះបាទ បទុមរាជាទី៣ (គ.ស.១៦៦០- គ.ស.១៦៧២)។ ចៅពញ្ញាមៅ បានទទួលមុខងារជាឧកញ៉ាអាធិកវង្សានិងបានកសាងនូវបន្ទាយសីមាមួយទៀតនៅ "ពុតឆ្លេ" នៅក្នុងខេត្តពលលាវ ។ លោកបានទទួលមរណភាពនៅក្នុង អាយុ ៩៨ឆ្នាំ ដោយបានបន្សល់ទុកកូនប្រុសម្នាក់ឈ្មោះ ម៉ឺន គាត ជាអ្នកបន្តវេន។

ម៉ឺន គាត ជាមន្ត្រីស្ថិតក្នុងរជ្ជកាលព្រះបាទ ស្រីធម្មរាជា ក្នុងឆ្នាំ១៧១៦ ម៉ឺន គាត ដែលត្រូវបានតែងតាំងជាចៅហ្វាយខេត្តបន្ទាប់ពីឪពុករបស់ខ្លួននោះ បានបង្វិចិត្តផ្លាស់ទីក្រុងរបស់ខ្លួននៅពុតឆ្លេ ខេត្តពលលាវ ទៅនៅឃ្លាំងវិញ ដែលជាអតីតទីក្រុងរបស់ស្មិទ្ធភូបាលគាត ទីនោះមានយុទ្ធសាស្ត្រល្អជាង ។

ម៉ឺន គាត បានធ្វើឲ្យប្រទេសមានសន្តិភាព យកចិត្តទុកដាក់ នឹងការងារសង្គមនិងសាសនា និងការរៀបចំទឹកដី ។ លោកបានអញ្ជើញមកកម្ពុជា ដើម្បីនិមន្តព្រះសង្ឃ ដែលមានការចេះដឹងជ្រៅជ្រះ ដើម្បីបង្រៀន "ធម្មវិន័យ" ដល់ព្រះពុទ្ធសាសនិកជននៅកម្ពុជាក្រោម ។

"ម៉ឺន គាត" បានទទួលមរណភាពនៅក្នុងអាយុ ៩០ឆ្នាំ បន្សល់ទុកកូនប្រុសម្នាក់ឈ្មោះ សូរ ។

ម៉ឺន សូរ ជំនួសឪពុករបស់លោកនៅឆ្នាំ១៧៥៨ នៅក្រោមរជ្ជកាលរបស់ព្រះស្រីសុរិយោពណ៌(ព្រះឧទ័យទី២ គ.ស.១៧៥៨ - គ.ស.១៧៧៥) ។ ម៉ឺន សូរ បានតវ៉ាប្រឆាំងការលុកលុយរបស់អណ្ណាម នៅក្នុងតំបន់បាយឆៅ និងបានធ្វើរបាយការណ៍ទៅថ្វាយព្រះមហាក្សត្រនៃប្រទេសកម្ពុជា ដើម្បីទទួល បាននូវកំឡាំងបន្ថែម ដើម្បីប្រឆាំងជាមួយពួកអណ្ណាម ។ លោកបានទទួលមរណភាពនៅក្នុងអាយុ ៧១ឆ្នាំ ។ កូនប្រុសរបស់លោកឈ្មោះ ម៉ឺន ណែម បានជំនួសលោកនៅឆ្នាំ១៧៩៦ នៅពេលព្រះបាទអង្គអេង (គ.ស.១៧៩៦ - គ.ស.១៨០៦) ពេលនោះប្រទេសកម្ពុជា បានឆ្លងកាត់នូវដំណាក់កាលដ៏លំបាក ដែល បានបន្តដល់ក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី២ (គ.ស.១៨០៦ - គ.ស.១៨៣៤) និងនៅក្រោមរជ្ជកាលម្ចាស់ ក្សត្រីយ៍អង្គម៉ី (គ.ស.១៨៣៤ - គ.ស.១៨៤១)។ ម៉ឺន ណែម ដែលបានរក្សាការតស៊ូទល់នឹងកងទ័ពអណ្ណាម នោះបានទទួលមរណភាពនៅក្នុងអាយុ ៨៩ឆ្នាំ ។

## **អំពីការចាតតាំងទឹកដីរបស់យួន ចូលមកទឹកដីកម្ពុជាក្រោម**

### *ដើមកំណើតនៃជនជាតិយួន*

ជនជាតិយួនមានដើមកំណើតនៅប្រទេសចិនប៉ែកខាងត្បូង ក្នុងខេត្តយូនណាន តាមវាលទំនាបនៃទន្លេយ៉ង់សេ Yang Tse ។ ពួកនេះមានឈ្មោះដើមហៅថា ណាមវៀត (Namviet) ជានណាម, ណាមវៃ, អាណ្ណាម ដាយវៀត ឬយ៉ួអើ (Yue) ដែលខ្មែរយើងហៅថាឈ្មោះថា យួន ៗនោះ។ ពូជសាសន៍យួនគ្មានជាប់ពូជ អំបូរជាមួយខ្មែរមនទេ។ យួនបានប្តូរឈ្មោះទៅជាវៀតណាមរហូតសព្វថ្ងៃ ក្នុងរជ្ជកាលយ៉ាឡុង ឆ្នាំ១៨០២ ហើយត្រូវបានចិនទទួលស្គាល់ក្នុងឆ្នាំ១៨០៤ ។



THE KHMER KAMPUCHEA KROM COMMUNITY

## ការរាតត្បាតនៃជាតិយួនមកលើដែនតុងកឹង

ដែនតុងកឹង ឬដីទំនាបទន្លេក្រហម (Delta du Fleuve Rouge ឬ Red River Delta) ដែលយួន ហៅថា "បាក់គី" (Bac KY) ឬដែលយួនកុម្មុយនិស្តនិយមហៅថា "បាក់បូ" (Bac Bo) ជាដីរបស់កុល សម្ពន្ធ័ម៉េវ (Meo) ម៉ុយ (Mois) ថៃ (Thai) មិន (Man) ។ ល ។

លុះដល់ឆ្នាំ១១១ មុនគ.ស ទើបជនជាតិយួនវាតទីមកលើតំបន់នេះ។ គេតាំងរាជធានីមួយឈ្មោះថា ក្រុងដុងគិញ (Dong Kinh) ដែលក្រោយមកប្តូរមកជា ហាណូយ រហូតសព្វថ្ងៃ។ ចំណែកឯជនជាតិដើមក៏នាំគ្នាភៀសខ្លួនឡើងទៅនៅលើភ្នំអស់ទៅ។ តុងកឹង ឬបាក់គីនេះ ស្ថិតនៅក្រោមការត្រួតត្រាចិនប្រហែល ១០០០ឆ្នាំ គិតពីឆ្នាំ១១១ មុនគ.ស រហូតដល់ឆ្នាំ៩៣៩ នៃគ.ស ។

## ការវាតទីរបស់ជនជាតិយួនមកលើនគរចំប៉ា

នគរចាម ឬចំប៉ានេះ លាតសន្ធឹងតាមឆ្នេរសមុទ្រចិន ចាប់តាំងពីខេត្តក្វាងបិញ (Quang Binh)រហូតដល់ខេត្តផាន់ ធៀត (Phang Thiet)។ ជនជាតិយួនបានវាតទីយកនគរចំប៉ាពីចាម ចាប់តាំងពីពី គ.ស៦០៥ រហូត គ.ស១៩៧០ គេប្រែ ឈ្មោះហៅថា អាណ្ណាម ឬ ដែលយួននិយមហៅថា "ទ្រុងគី" (Trung Ky) ពួកកុម្មុយនិស្តហៅថា "ទ្រុងបូ" (Trung Bo) ដែលមានរាជធានីឈ្មោះ ក្រុងវេ (Hue) ។ ទឹកដីចាម ត្រូវបានពួកយួនទន្ទ្រានយកទាំងស្រុង នៅក្នុងសតវត្សរ៍ទី១៧។

## ការវាតទីរបស់យួនមកលើទឹកដីកម្ពុជាក្រោម

ក្នុងមហិច្ឆតាលេបត្របាក់យកទឹកដីខ្មែរកម្ពុជាក្រោម យួនប្រើមធ្យោបាយជាយុទ្ធសាស្ត្រច្រើនជាងយកទឹកដីចំប៉ា។ យួនបានអនុវត្តយុទ្ធសាស្ត្រយូរអង្វែងរហូតជាង ៣០០ឆ្នាំ គឺពីឆ្នាំ១៦១៨ ដល់ ឆ្នាំ១៩៤៩ ទើបយកកម្ពុជាក្រោមបាន ប៉ុន្តែមិនមែនមានន័យថា យួនយកទឹកដីខ្មែរកម្ពុជាក្រោមស្របច្បាប់នោះទេ ។

*យុទ្ធសាស្ត្រទី១ យកស្រីស្អាត បុណ្យសក្តិ លុយកាក់ មកទាក់ទាញស្តេចខ្មែរ និងមន្ត្រីខ្មែរ*
*យុទ្ធសាស្ត្រទី២ បង្ហូរចូលនៃជនជាតិយួន រួចបញ្ឆៀតតាំងទីលំនៅលើទឹកដីខ្មែរ*
*យុទ្ធសាស្ត្រទី៣ កកូរកកាយផ្ទៃក្នុងឲ្យមានជម្លោះ រួចមកជួយធ្វើអន្តរាគមន៍*

## ល្បិចកលហោជីមិញ ក្នុងការវាតទីយកទឹកដីខ្មែរកម្ពុជាក្រោម

ដើម្បីយកទឹកដីខ្មែរកម្ពុជាក្រោមឲ្យបានពេញលេញ ហោជីមិញ (មេដឹកនាំដ៏ល្បីល្បាញបំផុតរបស់យួន) បានប្រើល្បិចកលដ៏ប៉ិនប្រសព្វក្នុងរូបភាពនយោបាយ ឯកភាពជនជាតិវៀតណាម ឯកភាពទឹកដីវៀតណាម (Unitleation des Ky) ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ដែលមានហោជីមិញជាប្រធាន។ នយោបាយទុច្ចរិតដែលហោជីមិញធ្វើដើម្បីយកដីខ្មែរគឺ

១-ទាមទារឯករាជ្យ ឯកភាពជនជាតិយួន។

២-ដេញបារាំងចេញពីឥណ្ឌូចិន ។

៣- ត្រួតត្រាឥណ្ឌូចិនជំនួសបារាំង

ហូជីមិញបានដើរតួជាតំណាងប្រជាពលរដ្ឋទាំងឡាយនៅឥណ្ឌូចិន តាំងពីឆ្នាំ១៩១៩។ [illegible] ហូជីមិញបានធ្វើញត្តិមួយក្នុងនាម ឥណ្ឌូចិន សុំចូលជួបលោកប្រធានាធិបតីអាមេរិក វៀលសឺន (Woodrow Wilson, ៤ មីនា ១៩១៣ - ៤ មីនា ១៩២១) នៅក្រុងប៉ារីស ។



* THE KHMER KAMPUCHEA ... *

## ប្រវត្តិសង្ខេបនៃគណបក្សកុម្មុយនិស្តឥណ្ឌូចិន

ទី១-សមាគមយុវជនបដិវត្តន៍យួន (Association de la Jeunesse Révolutionnaire du Vietnam) ហោជីមិញ កាលនោះមានឈ្មោះថា ង្វៀង អៃ ក្វឹក Nguyễn Ái Quốc ឬ Nguyễn Tất Thành បានដឹក នាំអ្នកស្នេហាជាតិយួន ដើម្បីបង្កើតសមាគមនេះឡើងនៅក្រុងកុងតុង ក្នុងប្រទេសចិនក្នុងគ.ស១៩២៥ ។ សមាគមនេះបង្កើតឡើងក្នុងគោលបំណងអប់រំជនជាតិយួនឲ្យមានស្មារតីជាតិនិយម។ សមាជិកសំខាន់ៗដែលបង្កើតសមាគមនេះមាន ហោជីមិញ, ហូទុងមៅ, ឡៃ ហុងសុង ផាំ វ៉ាន់ដុង ។ល។

លុះដល់ឆ្នាំ១៩២៧ លោក ជៀង កៃ ជៀក Chiang Kai-shek បានដេញពួកអ្នកជំនាញការរុស្ស៊ី ហើយនិងហោជីមិញឲ្យទៅម៉ូស្គូវិញ។ សមាជិកសំខាន់ៗខ្លះទៀតត្រូវពួកចិនចាប់បាន ហើយដាក់គុក ។

ដល់ឆ្នាំ១៩២៩ ឡៃ ហុងសុង ជាអ្នកទទួលខុសត្រូវចំពោះសមាគមជំនួសហូជីមិញ។ សមាគមនេះក៏ត្រូវលោយនៅពេលនោះទៅ ។ សមាជិកទាំងប៉ុន្មានបែកគ្នាជា ៣ក្រុម ហើយបានបង្កើតជាគណបក្ស ៣ ខុសៗគ្នា។

ទី១-គណបក្សកុម្មុយនិស្តឥណ្ឌូចិន

ទី២-គណបក្សកុម្មុយនិស្តអណ្ណាមិត

ទី៣-សហភាពកុម្មុយនិស្តឥណ្ឌូនចិន

ដំណឹងបាក់បែកគ្នានេះបានឮទៅដល់ ង្វៀង អៃ ក្វឹក ។ ពេលនោះ ង្វៀង អៃក្វឹកឬហោជីមិញកំពុងពួនសម្ងំនៅប្រទេសសៀម ។ គាត់កំកោះប្រជុំមេបក្សធំៗទាំង ៣ ដែលទើបបានបង្កើតនោះ ហើយ សុំឲ្យមេគណបក្សធំៗទាំង ៣លុបគណបក្សរបស់ខ្លួនចោលទាំងអស់ ហើយបង្កើតគណបក្សថ្មីមួយជំនួសវិញ។ គណបក្សថ្មីនោះ មានឈ្មោះថា គណបក្សកុម្មុយនិស្តវៀតណាម ដែលមានទីស្នាក់ការនៅក្រុង ហៃហ្វុង។ ដើម្បីឲ្យបានសម្រេចគោលបំណងរបស់គេ ដែលចង់ត្រួតត្រាឥណ្ឌូចិនទាំងមូលនោះ ង្វៀង អៃ ក្វឹក បានសម្រេចជាមួយនឹងសហការីជំនិតៗខ្លះ ដូចជា ផាំ វ៉ាន់ ដុង យ៉ ង្វៀង យ៉ាប់ ឆាង ថៃ ម៉ៃ ជាដើម ប្តូរឈ្មោះពីបក្សកុម្មុយនិស្តវៀតណាមមកជាបក្សកុម្មុយនិស្តឥណ្ឌូចិនវិញ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៣០ ។

ង្វៀង អាយ ក្វឹក បានលួចឆ្លងទៅប្រទេសចិន ត្រូវបានអង់គ្លេសចាប់ដាក់គុកនៅក្រុងហុងកុង ក្នុងឆ្នាំ១៩៣១ ។ ដូច្នេះពេលនោះយើងឃើញថា គណបក្សកុម្មុយនិស្តឥណ្ឌូចិនស្ទើរតែរលាយរូប ។

ង្វៀង អៃ ក្វឹក ដែលគេស្មានថា តែស្លាប់កាលពីឆ្នាំ១៩៣២ នៅក្រុងហុងកុងនោះ ក៏បានលេចមកក្នុងឆាកនយោបាយវិញ ដោយផ្លាស់ឈ្មោះជាហោជីមិញ ។ នៅឆ្នាំ១៩៤១ ហោជីមិញបានកោះហៅ សហការីសំខាន់ៗរបស់គាត់នៅក្នុងគណបក្សកុម្មុយនិស្តឥណ្ឌូចិនទៅប្រជុំជាសមាជនៅក្រុងស៊ីនស៊ី នៃប្រទេសចិន។ សមាជនេះបានសម្រេចបង្កើតរណសិរ្សមួយ ដែលមានឈ្មោះជាអក្សរកាត់ថារណសិរ្សវៀតមិញ។ គោលបំណងរបស់គេ គឺប្រមូលជនជាតិយួនគ្រប់ជាន់ថ្នាក់ ដើម្បី

ទី១-ភគក្បាលលុកលុយកម្ពុជាក្រោម ប្រទេសខ្មែរ និង ប្រទេសលាវ ។

ទី២-ច្បាំងកំចាត់បារាំង ហើយនិងជប៉ុន ។

ដូច្នេះយើងឃើញថា ពួកកុម្មុយនិស្តឥណ្ឌូចិនមានអង្គការប្រយុទ្ធខាងនយោបាយផង និងខាងយោធាផង។ ដោយសាររណសិរ្សវៀតមិញនេះ ពួកកុម្មុយនិស្តយួនបានភគក្បាលពេញប្រទេសទាំង ឡាយនៅឥណ្ឌូចិន "យួន កម្ពុជាក្រោម ខ្មែរ លាវ" ។

ក្រោយមកនៅថ្ងៃទី០២ កញ្ញា ១៩៤៥ ក្រោយដែលជប៉ុនបានប្រកាសចុះចាញ់ក្នុងសង្គ្រាមលោក លើកទី២ ហូជីមិញបានប្រកាសឯករាជ្យឲ្យប្រទេសវៀតណាម និងប្រកាសបង្កើតសាធារណរដ្ឋប្រជាធិ

THE KHMER KAMPUCHEA KROM COMMUNITY

គេយៀកណាម ។ ចំណែកឯព្រះចៅបៅដាយសុខចិត្តលះបង់រាជសម្បត្តិប្រគល់អំណាចទាំងអស់ឲ្យហោជីមិញ ។ ហោជីមិញក៏បានតែងតាំងស្តេចបៅដាយ ជាទីប្រឹក្សាជាន់ខ្ពស់នៃសាធារណរដ្ឋថ្មីនេះ។ពេលនោះ ដើម្បីឲ្យមានការគាំទ្រពីប្រទេសអាមេរិកាំង អង់គ្លេស និងពលរដ្ឋយួន ដែលមិនស្រឡាញ់លទ្ធិកុម្មុយនិស្តនោះ ហោជីមិញក៏បានប្រកាសលុបគណបក្សកុម្មុយនិស្តឥណ្ឌូចិនចោលកាលពីខែវិច្ឆិកា ១៩៤៥។ តែដើម្បីឲ្យស្រុី និងចិនកុម្មុយនិស្តរបស់ មៅ សេទុង និង សមមិត្តៗរបស់គាត់មានការទុកចិត្តហោជីមិញបានបង្កើតសមាគមមួយជំនួសគណបក្សកុម្មុយនិស្តឥណ្ឌូចិន ។ សមាគមនោះមានឈ្មោះ សមាគមឥណ្ឌូចិនខាងការសិក្សាលទ្ធិម៉ាក្ស (Association Indochinoise pour les Études Marxistes ឬ Indochinese Association for Marxist Studies) ដែលមានសកម្មភាពដូចគណបក្សកុម្មុយនិស្តឥណ្ឌូចិន ដដែល ។

ម្យ៉ាងទៀត អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រជាច្រើន គេបានសំគាល់ថាឆ្នាំ១៩៤១គឺជាឆ្នាំដែលឥណ្ឌូចិនចាប់ផ្តើមផ្ទុះសង្គ្រាមឡើងជាដំបូង ដោយហេតុថា ពួកយៀកមិញបានធ្វើការលុកលុយប្រទេស ទាំងឡាយនៅឥណ្ឌូចិន ។ ខែមករា ១៩៤៦ ហោជីមិញបានជាប់ឆ្នោតជាប្រធានាធិបតីវៀតណាម ។ ពេលនោះ ហោជីមិញ បានរៀបចំធ្វើជារណសិរ្សបង្រួបបង្រួមជាតិមួយឈ្មោះថា រណសិរ្សលៀងវៀត Lien Viet គណបក្សនយោបាយធំៗឯទៀតជាច្រើនបានចូលទៅក្នុងរណសិរ្សលៀងវៀតនេះផងដែរ ។

ចាប់តាំងពីពេលនេះមកហើយ ដែលគេឃើញរដ្ឋាភិបាលរបស់ហោជីមិញចាប់ផ្តើមរៀបចំអនុវត្តន៍នូវនយោបាយរបស់ខ្លួនឲ្យស្របទៅតាមកម្មវិធីនយោបាយរបស់គណបក្សកុម្មុយនិស្តឥណ្ឌូចិនគឺ ៖

- ទាមទារដីកម្ពុជាក្រោម
- ឯករាជ្យនិងឯកភាពវៀតណាម
- ដេញបារាំងពីឥណ្ឌូចិន
- ត្រួតត្រាឥណ្ឌូចិនជំនួសបារាំង

ក្នុងការទាមទារទឹកដីខ្មែរកម្ពុជាក្រោមនេះ ហោជីមិញបានប្រើកលល្បិចយ៉ាងប៉ិនប្រសព្វបំផុត ។ ហោជីមិញបានចុះហត្ថលេខាលើសេចក្តីព្រមព្រៀងជាមួយបារាំងចំនួន ៣លើករួចជាស្រេចទៅហើយ គឺសេចក្តីព្រមព្រៀងនៅក្រុងហាណូយចុះថ្ងៃទី៦ មិនា ១៩៤៦ (Accord Franco-Vietnamien du 6 Mars 1946 en Hanoi ឬ Accord Between France and the Democratic Republic of Vietnam, 6 March 1946)។ សេចក្តីព្រមព្រៀងនេះជាលទ្ធផលនៃការចរចាយ៉ាងស្វិតស្វាញរវាងហោជីមិញ និងបារាំង អំពីបញ្ហាបញ្ចូលទឹកដី ខ្មែរកម្ពុជាក្រោមទៅជាឯកភាពទឹកដីជាមួយវៀតណាម (យកទឹកដីខ្មែរបញ្ចូលជាទឹកដីយួន) ។ល។ សេចក្តីព្រមព្រៀងក្រុងដាឡាក់ ចុះថ្ងៃទី២៤ មេសា ១៩៤៦ (Accord de Dalat du 24 April 1946 ឬ Agreement of 24 April 1946 Between France and the Democratic Republic of Vietnam in Dalat)។ សេចក្តីព្រមព្រៀង នេះជាលទ្ធផលនៃសន្និសីទក្រុងដាឡាក់ រវាងគណៈប្រតិភូបារាំង និងគណៈ ប្រតិភូយៀកមិញ ស្តីអំពីការអនុវត្តន៍នូវសេចក្តីព្រមព្រៀងចុះថ្ងៃទី០៦ មិនា ១៩៤៦ ។

សទ្ធិសញ្ញាបណ្តោះអាសន្ននៅទីក្រុងហ្វុងតែណឺប្លូ ចុះថ្ងៃទី១៤ កញ្ញា ១៩៤៦ (Modus Vivendi du 14 September 1946 a Fontainebleau) សន្ធិសញ្ញាបណ្តោះអាសន្ននេះ បានមកពីសន្និសីទមួយយ៉ាងយូរ និងយ៉ាងលំបាករវាងយួន និង បារាំង ស្តីអំពីបញ្ហាកម្ពុជាក្រោម ឯករាជ្យនិងឯកភាពវៀតណាម បញ្ហាសហព័ន្ធឥណ្ឌូចិន (Federal Indochinoise ឬ Indochinese Federation) ។ល។

សេចក្តីព្រមព្រៀង ឬសទ្ធិសញ្ញាបណ្តោះអាសន្នទាំង៣លើកនេះសុទ្ធតែជាបញ្ហាដែលទាក់ទងនឹងប្រទេសខ្មែរយើងទាំងអស់ ប៉ុន្តែគេចុះហត្ថលេខាមិនឲ្យខ្មែរយើងចូលរួមជាមួយផងទេ។ នេះ[illegible]ល្បិចរបស់កុម្មុយនិស្តឥណ្ឌូចិនក្នុងការរៀបត្រួតត្រាប្រទេសទាំងអស់នៅឥណ្ឌូចិន ។

THE KHMER KAMPUCHEA KROM CO.

ម្យ៉ាងទៀតដោយហេតុថា គោលបំណងរបស់គេខាងលើនេះ មិនបានសម្រេច ពួកយួនកុម្មុយនិស្ត ក៏បានចាប់ផ្ដើមវាយបារាំងចេញមុខមែនទែន តាំងពីថ្ងៃទី១៩ ធ្នូ ១៩៤៦ ។

ក្នុងការប្រយុទ្ធជាមួយបារាំងនេះ រណសិរ្សលៀងវៀត បានដើរតួយ៉ាងសំខាន់នៅក្នុងប្រទេសយួន ចំណែកឯពួកវៀតមិញវិញ គេខំប្រឹងប្រែងយ៉ាងសម្បើមនៅកម្ពុជាក្រោម នៅប្រទេសខ្មែរនិងលាវ ។

ចម្បាំងរវាងបារាំងនិងយួនបានចប់ (ក្រោយដែលបារាំងចាញ់សង្គ្រាមនៅឌៀងបៀងភូកាលពីថ្ងៃទី ៧ ឧសភា ១៩៥៤) ដោយសន្និសីទហ្សឺណែវ ស្ដីអំពី បញ្ហាឥណ្ឌូចិន ដែលបានបញ្ចប់កិច្ចការរបស់ខ្លួននៅថ្ងៃទី២០កក្កដា១៩៥៤ដោយចែកប្រទេសយួនជា ២ តាមបណ្ដោយខ្សែស្របទី១៧ ។ តែអ្វីដែលគេធ្វើបានសម្រេចជោគជ័យតាមផែនការយុទ្ធសាស្ត្ររបស់គេនោះគឺ

- យកបានទឹកដីកម្ពុជាក្រោមជាស្ថាពរ
- ប្រទេសយួនបានឯកភាពពេញលេញ
- បារាំងចាកចេញពីឥណ្ឌូចិន
- ឯកភាពជាតិ និងឯកភាពទឹកដីរបស់យួន (យកទឹកដីខ្មែរបញ្ចូលជាទឹកដីយួន)

ចំពោះយុទ្ធសាស្ត្រ សហព័ន្ធឥណ្ឌូចិនកំពុងអនុវត្តសព្វថ្ងៃ។

អំពីអាណានិគមបារាំងកាត់ទឹកដីខ្មែរឲ្យយួន

មុននឹងដកអាណានិគមរបស់ខ្លួនចេញពីទឹកដីកម្ពុជាក្រោម បារាំងបានបន្សល់ទុកនូវអនុស្សាវរីយ៍ដ៏សែនឈឺចាប់បំផុត ធ្វើឲ្យប្រជារាស្ត្រខ្មែរកម្ពុជាក្រោមទទួលរងទុក្ខវេទនាដ៏សែនខ្លោចផ្សា នោះគឺធ្វើច្បាប់លេខ ៤៩-៧៣៣ កាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យយួន។

ខ្លឹមសារនៃច្បាប់ទាំងស្រុងមានដូចតទៅ ៖

Loi No. 49-733 du 4 Juin 1949 modifiant le statut de la Cochinechine dans l'Union française.

Après avis de l'Assemblée nationale de l'Union française, L'Assemblée nationale et le Conseil de la République ont délibéré, L'Assemblée nationale à adopté, Le Président de la République promulgue le loi dont la teneur suit:

Art. 1er – Dans le cadre fixé à L'article 60 le la Constitution de la République francaise et après l'avis émis, dans sa séance du 23 april 1949, par l'Assemblée territoriale de Cochinchine, le statut de la Cochinchine est modifié dans les conditions prévues à l'article ci-après.

Atr. 2.- Le territoire de la Cochinchine est rattaché à l'Etat associé du Viet-Nam suivant les termes de la declaration commune du 5 juin 1948 et de la declaration du Gouvernement française du 19 août 1948. La Cochinchine cesse en conséquence d'avoir le statut de territoire d'outre-mer.

Art. 3- En cas de changement du statut du Viet-Nam, le statut de la Cochinchine fera l'objet d'une nouvelle deliberation des assemblées prévues à l'article 75 de la Constitution (Titre VIII: De l'Union française).

La présente loi sera execute comme loi de l'Etat. Fait à Toulon, le 4 Juin 1949.

VINCENT AURIOL HENRI QUEUILLE. PAUL COSTE-FL...

Le Président de la République Le president du conseil des ministres, Le Ministère de la France d'outre-mer

THE KHMER KAMPUCHEA KROM COMMUNITY

បកប្រែក្រៅផ្លូវការ

ច្បាប់លេខ ៥៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩

យោង: មតិរដ្ឋសភានៃសហភាពបារាំង រដ្ឋសភា និងក្រុមប្រឹក្សានៃសាធារណរដ្ឋបារាំងបានសម្រេច និង អនុម័ត ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ប្រកាសឲ្យប្រើច្បាប់ដូចតទៅ ៖

**មាត្រា១** - យោងមាត្រា៦០ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំង និងយោងមតិ សភាកូសាំងស៊ីន នាសម័យប្រជុំថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៤៩ លក្ខន្តិកៈទឹកដីកូសាំងស៊ីន ត្រូវបានកែប្រែតាមមាត្រា ដូចមានចែងខាងក្រោម ។

**មាត្រា២** -ទឹកដីកូសាំងស៊ីន ត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម យោងតាមសេចក្តីប្រកាសរួមកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៤៨ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំងកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៨ ទឹកដីកូសាំងស៊ីន ឈប់ស្ថិតនៅក្នុងលក្ខន្តិកៈ ជាទឹកដីរបស់បារាំង ឯនាយសមុទ្រទៀតហើយ។

**មាត្រា៣** -ក្នុងករណីលក្ខន្តិកៈប្រទេសវៀតណាម ត្រូវកែប្រែ ទឹកដីកូសាំងស៊ីន ត្រូវទុកជាកម្មវត្ថុនៃការសម្រេចរបស់សភាខាងលើ ដូចមានចែងក្នុងមាត្រា៧៥ ជំពូក៨ នៃរដ្ឋធម្មនុញ្ញសហភាពបារាំង។

ច្បាប់នេះ នឹងត្រូវអនុវត្ត ដូចជាច្បាប់រដ្ឋ។

ធ្វើនៅទូឡុង, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩

ហត្ថលេខា

| | | |
|---|---|---|
| វ៉ាំងសង់ អូរីយ៉ុល | ហង់រីកើយ | ប៉ូល កូស្តផ្លូរេត |
| ប្រធានាធិបតី | នាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ |

## យួនកាន់កាប់ទឹកដីខ្មែរកម្ពុជាក្រោមសព្វថ្ងៃ គឺជាការខុសច្បាប់

វៀតណាមពុំដែលបានធ្វើចម្បាំងដណ្តើមយក (Conquer)ទឹកដីកម្ពុជាក្រោមម្តងណាសោះឡើយ ។ ការជ្រៀតចូលនៃជនជាតិយួនក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជានេះ បានត្រូវធ្វើឡើងដោយសារតែចម្បាំងក្នុងស្រុករវាងព្រះរាជវង្សានុវង្សនិងក្សត្រគ្រងរាជ្យ គឺចម្បាំងដែលស្តេចបះបោរទៅពឹងយួនឲ្យមក ជួយអន្តរាគមន៍តែប៉ុណ្ណោះ ។ ដូចជាការជ្រៀតចូលទឹកដីខ្មែរដំបូងបង្អស់ គឺផ្តើមឡើងដោយកល្បិចរបស់ស្រីយួនដែលត្រូវជាមហេសីរបស់ស្តេចជ័យជេដ្ឋាទី២ជាមេគំនិត។កំប៉ុន្តែដំបូងឡើយគឺគ្រាន់តែជាសេចក្តីអនុញ្ញាត (Autorisation ឬ Authorization) ដែលព្រះបាទជ័យជេដ្ឋាទី២ បានប្រទានឲ្យយួនខ្ចីចំនួន ៥ឆ្នាំ ដើម្បីតាំងហាងជំនួញនៅផ្នែកចុងខាងត្បូងបំផុតរបស់ប្រទេសកម្ពុជា គឺនៅកំពុងក្របី (បច្ចុប្បន្ន ព្រៃនគរ) និង ម៉ូយ ស៊ុយ (Moi Xu) តែប៉ុណ្ណោះ ។ ដោយអាស្រ័យមានសេចក្តីអនុញ្ញាតបែបនេះ មហេសី ព្រះបាទជ័យជេដ្ឋាទី២ បានដឹកនាំឲ្យជនជាតិយួនចូលមកប្រទេសកម្ពុជាផ្នែកនោះ ហើយតាំងទីលំនៅ យ៉ាងស្រួល ។ ចាប់ពីពេលនោះមក បញ្ហាកំពង់ក្របី និង ម៉ូយ ស៊ុយ បានក្លាយទៅជាបញ្ហាមួយដោះ ស្រាយពុំរួច ។ តាមចុតហ្មាយរបស់ក្សត្រីយួនរូបនេះ បានឲ្យដឹងថា ប្រទេសអណ្ណាមបានសុំប្រើប្រាស់ ដីនេះតែក្នុងរយៈពេល៥ឆ្នាំប៉ុណ្ណោះ ដោយប្រទេសអណ្ណាមបានលើកហេតុផលថា ខ្លួនត្រូវការឲ្យទ័ព របស់ខ្លួនសំចត ដើម្បីស្លអាវុធច្បាំងជាមួយចិន (អញ្ជើញអានពង្សាវតារប្រទេសកម្ពុជា ក្បាលទី៣២)។

ក្រោយមក ស្តេចប្រទេសខ្មែរបានសុំឲ្យស្តេចប្រទេសអណ្ណាមប្រគល់ដីកោះក្របី និងម៉ូយ ស៊ុយ មកឲ្យខ្មែរវិញចំនួនពីរលើក លើកទី១ នៅឆ្នាំ១៦៤៥ ធ្វើឡើងដោយព្រះបាទពញាតូ (ពង្សាវតារប្រទេសកម្ពុជាច្បាប់ស្លឹករឹត ក្បាលទី៣២)និងលើកទី២ នៅក្នុងឆ្នាំ១៦៥៣ ធ្វើឡើងដោយព្រះបាទអង្គ... ការតម្រូវឲ្យប្រគល់សងខ្មែរវិញលើកទីមួយ ក្សត្រីជាតិយួនមេម៉ាយពីព្រះបាទជ័យជេដ្ឋាទី២ ...ឆ្លើយ...

THE KHMER KAMPUCHEA KROM COMMUN...

ថា ប្រទេសអណ្ណាមកំពុងជាប់ច្បាំងជាមួយប្រទេសចិន មានសេចក្តីត្រូវការជាចំបាច់ចំពោះដីនោះ ហើយអង្វរស្តេចខ្មែរឲ្យទុកដីនោះឲ្យយួនប្រើប្រាស់សិន ។ ក្សត្រីជាតិសាសន៍យួននេះបានសន្យាយ៉ាងជាក់លាក់ថា នឹងប្រគល់ដីទាំងនោះមកឲ្យខ្មែរវិញ ពេលណាអធិរាជអាណាចក្រអណ្ណាមលែងត្រូវការ។

ក្រោយមកព្រះបាទអង្គចន្ទ ក៏បានស្នើឲ្យយួនប្រគល់ដីទាំងអស់នោះមកឲ្យខ្មែរម្តងទៀត។ លើកនេះ ក្សត្រីមេម៉ាយជាតិយួនអណ្ណាមដដែលបានសុំឲ្យព្រះអង្គចន្ទឲ្យទុកដីកោះក្របីនិងម៉ូយស៊ុយ នេះ ជាចំណែកផ្តាច់មុខរបស់យួន ព្រោះព្រះនាងមានឋានៈជាក្សត្រីយានីប្រទេសខ្មែរ (មហេសីក្សត្រ សោយរាជ្យព្រះបាទជ័យជេដ្ឋាទី២)។

ដូច្នេះដីទាំងពីរចំណែកដ៏ធំ គឺម៉ូយ ស៊ុយ និង កោះក្របី (ព្រៃនគរ) ដែលបានធ្លាក់ចូលទៅក្នុងដៃរបស់យួនអណ្ណាម គឺដោយល្បិចកលទុច្ចរិតរបស់យួន ។ ពុំមែនស្តេចខ្មែរប្រគល់ឲ្យយួននោះទេ។

ក្រោយមកទៀត ពួកយួនបានពង្រីកទឹកដីនៅប៉ែកខាងក្រោមនេះឥតឈប់ឈរ ដោយពួកវាបានឆ្លៀតធ្វើការនៅក្នុងពេលណា ដែលស្តេចខ្មែរឈ្លោះទាស់ទែងច្បាំងដណ្តើមរាជ្យគ្នា ។

នៅឆ្នាំ១៧៨៥ យួនបានលើកទ័ពចំនួន ២០.០០០នាក់មកជួយច្បាំងឧបរាជ នន់ ទល់ និងព្រះអង្គសូរ។ បន្ទាប់ពីព្រះអង្គម្ចាស់ សូរ ទទួលបរាជ័យ ពួកកងទ័ពយួនទាំងនោះ បានចូលទៅតាំងទីលំនៅដោយស្រួលនៅកម្ពុជាក្រោម ។

ពេលដែលយួនបានមកតាំងទីលំនៅបានចំនួនច្រើនល្មមហើយ ពួកយួនទាំងនោះក៏ចាប់ផ្តើមចែកទឹកដីជាស្រុកតូចៗ ឋិតនៅក្រោមការត្រួតត្រារបស់មេទ័ពយួនម្នាក់កាន់កាប់អំណាចស៊ីវិល និងយោធាតាំងនៅព្រៃនគរ ទោះបីពេលនោះ នៅបណ្តាខេត្តចំនួនច្រើនបានកាន់កាប់ជាផ្លូវការដោយមន្ត្រីខ្មែរ ដែលមានងារថា ចៅហ្វាយស្រុក ឬក្រឡាពាសក៏ដោយ។ ជានិទាឃរណ៍មួយទៀត ដូចជាការកេតទីចូលកាន់កាប់ (prise possession) ខេត្តមីថរ និង វិញឡុង ។ យួនអណ្ណាមបានបន្លំធ្វើទ័ពខ្មែរចូលកាន់កាប់ខេត្តទាំងពីរនេះអស់ពីរលើក លុះមិនសម្រេចស្តេចយួនក៏ចេញមុខឲ្យទ័ពយួនដណ្តើមខេត្តទាំងនោះតែម្តង ។ រឿងរបៀបនេះត្រូវយួនប្រើទៀតក្នុងឆ្នាំ១៧៨៥ ក្នុងការដណ្តើមយកខេត្តស្រុកទ្រាំង ។

ដូច្នេះពីដំណាក់ការមួយជាបន្តបន្ទាប់ ប្រជាពលរដ្ឋខ្មែរបានបះបោរក្រោកឡើងប្រឆាំងនឹងយួនគ្មានឈប់ឈរជាការបញ្ជាក់យ៉ាងច្បាស់ថា គ្មានស្តេចខ្មែរអង្គណាមួយ គ្មានរាស្ត្រខ្មែរណាម្នាក់បានប្រគល់ឬព្រមបោះបង់ចោលទឹកដីកម្ពុជាក្រោម ឲ្យពួកយួនឡើយ រហូតដល់ធ្វើឲ្យលោក ម៉ូរ៉ា (Moura) ប្រវត្តិវិទូជនជាតិបារាំងដ៏ល្បីល្បាញបានសរសេរយ៉ាងក្បោះក្បាយពីទឹកចិត្តដ៏អង់អាចក្លាហាននៃប្រជារាស្ត្រខ្មែរដែលយើងសូមដកស្រង់ខ្លះៗមកជូនជ្រាបដូចតទៅ៖

បើខ្មែរបានបណ្តោយឲ្យគេពន្លះស្បែក (ដណ្តើមដី) ដោយគ្មានពាក្យអ្វីតវ៉ានោះ យើងគ្មានពាក្យអីត្រូវនិយាយទេ តែប្រជារាស្ត្រខ្មែរមិនដែលនៅស្ងៀមឬបោះបង់ការតវ៉ាទាមទារទេដូច្នេះទៅអនាគតខ្មែរនឹងទាមទារមកវិញ។ វិធានស្តីអំពីអាជ្ញាយុកាលមិនអាចផុតលេត់ទេ។ ការទាមទារមកវិញជាការសមស្របចំពោះយួន ដែលតែងតែបានគំរាមកំហែងយកដីកម្មសិទ្ធិរបស់អ្នកជិតខាង។

**ទឹកដីកម្ពុជាក្រោមបច្ចុប្បន្ន**

កម្ពុជាក្រោម ជាអតីតទឹកដីនៃព្រះរាជាណាចក្រកម្ពុជាស្ថិតនៅខាងកើតឆៀងខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នជាចំណែកមួយនៃទឹកដីសាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូង (South Vietnam) ។ កម្ពុជាក្រោមត្រូវអាណានិគមបារាំងកាត់ផ្តាច់ពីកម្ពុជាផ្តល់ទៅឱ្យអាណាចក្រវៀតណាម



THE KHMER KAMPUCHEA KROM COMMUNITY

ធ្វើជាអាណានិគមបន្តរហូតដល់សព្វថ្ងៃក្រោមច្បាប់អាណានិគមបារាំង លេខ ៤៩-៧៣៣ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ១៩៤៩ នៅទីក្រុង Toulon នៃប្រទេសបារាំង ។

កាលពីសម័យដើម ទឹកដីកម្ពុជាក្រោម គេហៅថា កម្ពុជាទឹកលិច ឬកម្ពុជាក្រោម (កម្ពុជាប៉ែកខាងក្រោម)ហើយគេអាចហៅបានម្យ៉ាងទៀតថា ដែនដីសណ្តទន្លេមេគង្គ (Mekong Delta)។ នៅសម័យអាណានិគមបារាំងត្រួតត្រាឥណ្ឌូចិន ទឹកដីកម្ពុជាក្រោមត្រូវបានបារាំងហៅថា Basse Cochinchine (កូសាំងស៊ីនក្រោម) ។

ចំពោះផ្ទៃដី និងចំនួនប្រជារាស្ត្រខ្មែរដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោមសព្វថ្ងៃ នៅមានបញ្ហាស្មុគស្មាញណាស់ ពីព្រោះពុំមានវិជ្ជាស្ថានជាតិណាមួយបានធ្វើជំរឿនឬកំណត់ឱ្យបានច្បាស់លាស់ទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ យើងបានធ្វើការសិក្សាស្រាវជ្រាវតាមឯកសារដើមសម័យអាណានិគមបារាំងត្រួតត្រាឥណ្ឌូចិន បានបង្ហាញឱ្យឃើញថា ទឹកដីកម្ពុជាក្រោមមានទំហំផ្ទៃដី ៦៨.៩៦៥គីឡូម៉ែត្រក្រឡា។ តួលេខនេះគិតតាមឯកសារបារាំងក្នុងឆ្នាំ១៩៥៥ព្រោះនៅពេលនោះអាណានិគមបារាំងបានបែងចែកទឹកដី នៅឥណ្ឌូចិនចំនួន ៥ប្រទេស ដើម្បីងាយស្រួលក្នុងការត្រួតត្រា គឺ:

១ ប្រទេសយួន មានផ្ទៃដី ១០៣.០០០គីឡូម៉ែត្រ ។

២ ប្រទេសចម្ប៉ា មានផ្ទៃដី ១៨៤.០០០គីឡូម៉ែត្រ ។

៣ ប្រទេសលាវ មានផ្ទៃដី ២៣៦០០០គីឡូម៉ែត្រ ។

៤ ប្រទេសកម្ពុជា មានផ្ទៃដី ១៨៥.០០០គីឡូម៉ែត្រ ។

៥ កម្ពុជាក្រោម មានផ្ទៃដី ៦៥.០០០គីឡូម៉ែត្រ ។

បច្ចុប្បន្ន ប្រទេសកម្ពុជាប្រកាសជាផ្លូវការថាមានផ្ទៃដី ១៨១.០៣៥គីឡូម៉ែត្រ។ ដូច្នេះទឹកដីកម្ពុជាក្រោម ត្រូវកើនបន្ថែមចំនួន ៣.៩៦៥គីឡូម៉ែត្រ បូកនឹង ៦៥.០០០គីឡូម៉ែត្រ ត្រូវជា ៦៨.៩៦៥គីឡូម៉ែត្រ (185.000គីឡូម៉ែត្រ - 181.035គីឡូម៉ែត្រ + 65.000គីឡូម៉ែត្រ = 68.965គីឡូម៉ែត្រ) ។

រីឯចំនួនប្រជារាស្ត្រខ្មែរនៅកម្ពុជាក្រោមវិញ យើងបានជំរឿនដោយផ្អែកទៅលើឯកសារចំនួន ៥ ដូចខាងក្រោម:

ទី១ តួលេខសម្រង់ស្ថិតិខ្មែរកម្ពុជាក្រោមរបស់រដ្ឋាភិបាលអាណានិគមបារាំងនៅឆ្នាំ១៩២៤ មាន ៨០.០០០ (ប្រាំបីម៉ឺន)នាក់ ។

ទី២ តួលេខស្រង់ស្ថិតិរបស់រណសិរ្សរំដោះកម្ពុជាក្រោមនៅឆ្នាំ១៩៦២ មាន ៤.០៤២.៥០០ (បួនលានបួនម៉ឺនប្រាំពីរពាន់ប្រាំរយ)នាក់ ។

ទី៣ សេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់លោកប្រធានាធិបតីវៀតណាម ង្វៀន វ៉ាន់ ធីវ នៅទីក្រុងព្រែកឬស្សីក្នុងឆ្នាំ១៩៦៩ថា ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមមានប្រមាណជាង ៤.០០០.០០០ (បួនលាន)នាក់

ទី៤ ឯកសារសមាគមខ្មែរកម្ពុជាក្រោមនៅប្រទេសបារាំងឆ្នាំ១៩៦៩ បានសរសេរថា ខ្មែរនៅកម្ពុជាក្រោមមានចំនួន ៤.៥០០.០០០ (បួនលានប្រាំសែន)នាក់ ។

ទី៥ តួលេខបូកសរុបប្រជារាស្ត្រខ្មែររបស់រដ្ឋាភិបាលខ្មែរនៅសាលសន្និសីទចតុម្មុខក្នុងឆ្នាំ១៩៧០ ឃើញប្រជារាស្ត្រខ្មែរនៅកម្ពុជាក្រោមមានចំនួន ៤.៥០០.០០០នាក់ ។ រីឯនៅកម្ពុជានាពេលនោះ ពលរដ្ឋខ្មែរមានចំនួនជិត ៧.០០០.០០០ (ប្រាំពីរលាន)នាក់ ។

ដូច្នេះ បានសេចក្តីថា សព្វថ្ងៃនេះ ពុំមានឯកសារណាមួយ ឬប្រភពណាមួយបានធ្វើជំរឿនស្ថិតិប្រជារាស្ត្រ ខ្មែរកម្ពុជាក្រោមឱ្យបានច្បាស់លាស់ពិតប្រាកដទេ ។ ប៉ុន្តែ បើផ្អែកតាមតួលេខខាងលើដែលអាច យកជាការបាននោះ គិតមកដល់ដំណាច់ឆ្នាំ២០១៤ ឃើញថា នៅកម្ពុជាក្រោម មានប្រជារាស្ត្រខ្មែររស់



THE KHMER KAMPUCHEA KROM COMMU

នៅប្រមាណជាង ១៨លាននាក់ ដូចនៅកម្ពុជាដែរ ។ របៀបធ្វើជំរឿនប្រជាជន (Recencement de la Population ឬ Population census) គឺគិតកំណើនប្រជាពលរដ្ឋក្នុង ២០ឆ្នាំម្តង បានសេចក្តីថា ២០ឆ្នាំក្រោយមក ឆ្នាំ១៩២៨ - ១៩៤៨ មាន ១.៦០០.០០០នាក់ (៨០.០០០ x ២០ = ១.៦០០.០០០)។ ២០ឆ្នាំក្រោយមកទៀត ឆ្នាំ១៩៤៨ ដល់ ១៩៦៨ មាន ៣.២០០.០០០នាក់។ល។ គិតមកដល់ឆ្នាំ២០១៨ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម មានចំនួនជាង ១៨លាននាក់ ប្រហាក់ប្រហែលគ្នានឹងប្រជាពលរដ្ឋខ្មែរនៅកម្ពុជានេះដែរ។
ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ៩៥% ជាកសិករ ៣% ជាអ្នករដ្ឋការ ២% ជាអ្នកជំនួញ។ ៨៥% មិន ចេះអក្សរ ស្ត្រី ៩៩% មិនចេះអក្សរខ្មែរ។ តំបន់ដែលប្រជាពលរដ្ឋខ្មែររស់នៅច្រើនជាងគេ គឺខេត្តព្រះត្រពាំង (TraVinh) ខេត្តឃ្លាំង (Soc Trang) ពលលាវ (Bac Lieu) មាត់ជ្រូក (Chau Doc) ក្រមួនស (Kien Giang) ពាម (Ha Tien) ព្រែកឫស្សី (Can Tho) និងខេត្តទឹកខ្មៅ (Ca Mau)។ ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ៨៥% មិនចេះអក្សរ ។

**អំពីសង្គមសាស្ត្រ:**

ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ជាជាតិសាសន៍ស្លូតត្រង់ គោរពជំនឿព្រះពុទ្ធសាសន៍ ៩៩% ។ ការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម មានទំនៀមទម្លាប់ វប្បធម៌ ប្រពៃណីដូចប្រជាពលរដ្ឋខ្មែរនៅកម្ពុជា ១០០% គ្រាន់តែខុសគ្នាត្រង់សម្លៀកបំពាក់និងសំនៀងភាសាបន្តិចបន្តួចតែប៉ុណ្ណោះ។ នៅកម្ពុជាក្រោម មានវត្តព្រះពុទ្ធសាសនាខ្មែរជាង ៥៦៧វត្ត មានព្រះសង្ឃគង់នៅជាង ២០.០០០អង្គ ។ វត្តព្រះពុទ្ធសាសនានិងព្រះសង្ឃជាព្រលឹងនៃជាតិខ្មែរកម្ពុជាក្រោម។ វត្តជាទីប្រជុំជន ជាកន្លែងអប់រំសីលធម៌ ជាកន្លែងបណ្តុះបណ្តាលធនធានមនុស្ស ជាកន្លែងផ្តល់ព័ត៌មានផ្សព្វផ្សាយព័ត៌មាន។ល។ ការទាក់ទងគ្នាក្នុងសង្គមខ្មែរកម្ពុជាក្រោម គឺជាភាសាខ្មែរនិងអក្សរខ្មែរ។ រីឯការប្រើប្រាស់ជាផ្លូវការ គឺភាសានិងអក្សរសាស្ត្រវៀតណាម។

**អំពីវប្បធម៌**

មជ្ឈមណ្ឌលផ្សាយវប្បធម៌សំខាន់បំផុតនៅកម្ពុជាក្រោម គឺស្ថិតនៅក្នុងវត្តព្រះពុទ្ធសាសនាទាំង ៥៦០វត្ត។ វត្តព្រះពុទ្ធសាសនាទាំងនេះហើយដែលជាមូលដ្ឋានដ៏រឹងមាំក្នុងការការពារពូជសាសន៍ វប្បធម៌ អក្សរសាស្ត្រ ភាសាសាស្ត្រនិងទំនៀមទម្លាប់ ប្រពៃណីខ្មែរនៅកម្ពុជាក្រោមឱ្យរស់គង់មានជីវិតរហូតដល់សព្វថ្ងៃ។ ការសិក្សារៀនសូត្រ វប្បធម៌ អក្សរសាស្ត្រខ្មែរ គឺមានតែក្នុងវត្តអារាមប៉ុណ្ណោះ។ អាជ្ញាធរអាណានិគមវៀតណាមមិនអនុញ្ញាតឱ្យមានសាលារៀនភាសាខ្មែរនៅតាមភូមិស្រុកឡើយ ។

ពលរដ្ឋខ្មែរកម្ពុជាក្រោមគោរពទំនៀមទម្លាប់វប្បធម៌របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនបំផុតដូចជាពិធីអាពាហ៍ពិពាហ៍ បុណ្យបូជាសព បុណ្យក្នុងព្រះពុទ្ធសាសនា បុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ អកអំបុក សំពះ ព្រះជាដើម។ រីឯសម្លៀកបំពាក់មានការប្រែប្រួលច្រើន ដោយសារអាណានិគមវៀតណាម បានបង្ខំឱ្យ ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមស្លៀកពាក់តាមបែបប្រពៃណីវៀតណាម។ ដូចនេះ ការស្លៀកពាក់តាមបែប ប្រពៃណីខ្មែរមានតិចតួចបំផុត ស្ទើរតែគ្មានតែម្តង ។

**អំពីសេដ្ឋកិច្ច**

សេដ្ឋកិច្ចសំខាន់បំផុតនៅកម្ពុជាក្រោម គឺកសិកម្ម ។ ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ៩៥% ជាកសិករ ប៉ុន្តែពុំបានធ្វើឱ្យជីវភាពរបស់ពួកគេធូរធារឡើយ ដោយសារថា កសិផលទាំងនោះត្រូវបិតនៅក្រោមការត្រួតត្រារបស់អាណានិគមវៀតណាមយ៉ាងតឹងរ៉ឹងបំផុត ។

នៅឆ្នាំ១៩៧៥ ពួកកុម្មុយនីស្តវៀតណាមបានត្រួតត្រាអំណាចនៅលើទឹកដីវៀតណាមទាំងមូល ។

THE KHMER KAMPUCHEA KROM COMMUNITY

ចាប់ពីពេលនោះមកអាជ្ញាធរអាណានិគមវៀតណាមបានរឹបអូសយកដីស្រែប្រជាពលរដ្ឋខ្មែរទាំងស្រុងមកទុកជាសម្បត្តិរួមបង្កើតទៅជាសហករណ៍ ។ ទន្ទឹមនឹងនោះ រដ្ឋអំណាចអាណានិគមវៀតណាម បាន ចាប់ផ្តើមកេណ្ឌមនុស្សជីកព្រែកខ្វាត់ខ្វែង ដែលពួកអាណានិគមយួនហៅថា នយោបាយទឹកដើម្បីស្រោចស្រពដំណាំកសិកម្ម ។ ផ្ទុយទៅវិញក្រោយពីជីកព្រែករួច អាជ្ញាធរអាណានិគមវៀតណាមបែរជាបញ្ជូនប្រជាជនយួនទៅរស់នៅតាមភ្លឺព្រែកទាំងនោះ ហើយក៏ចាប់ផ្តើមចែកដីស្រែជាថ្មីឡើងវិញ។ ពេលនោះ ហើយដែលប្រជាពលរដ្ឋខ្មែរត្រូវធ្លាក់ខ្លួនក្រីក្រវេទនាជាទីបំផុត ព្រោះពុំមានដីស្រែចំការ និង មុខរបរពិត ប្រាកដហើយក៏បង្ខំចិត្តដើរស៊ីឈ្នួលប្រជាជានយួនតាមតំបន់ផ្សេងៗ ។ រីឯជនជាតិយួនវិញ គេបានប្រជ្រៀតចូលរស់នៅក្នុងតំបន់ខ្មែរ និងមានដីស្រែចំការយ៉ាងច្រើនក្រាស់ក្រែលថែមទៀត ។ បច្ចុប្បន្ននៅពេលប្រជារាស្ត្រខ្មែរធ្លាក់ខ្លួនក្រីក្រ ពួកជនជាតិយួន (មិនដឹងបានប្រាក់មកពីណា) បានដើរទិញដីស្រែ ចំការរបស់ប្រជាពល រដ្ឋខ្មែរ ដែលនៅសេសសល់បន្តិចបន្តួចជាដើមចុងក្រោម។ ដូច្នេះប្រជាពលរដ្ឋខ្មែរត្រូវក្លាយជាទាសករ នៅលើទឹកដីកំណើតរបស់ខ្លួនយ៉ាងវេទនាបំផុត ។ ចំណែកឯក្រុមហ៊ុន សិប្បកម្ម រោងចក្រ ពិសេសរោង ចក្រកាត់ដេរសម្លៀកបំពាក់ អាជ្ញាធរអាណានិគមវៀតណាម មិនបានពង្រីកទៅ ដល់តំបន់ប្រជារាស្ត្រខ្មែរ រស់នៅឡើយ ។

-១៩-

សហគមន៍ខ្មែរកម្ពុជាក្រោម
THE KHMER KAMPUCHEA KROM COMMUNITY

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤




(DENSITÉ DU PEUPLEMENT KHMER EN 1945)
Ministère de l'Information du Cambodge (1962)









ប្រទេសកម្ពុជា
KAMPUCHEA (CAMBODIA)
ប្រទេស វៀតណាម
VIET NAM
RAONK DAMREI
TOUL TA MAOK (CHHEU TEAL MUY)
CHANGVA TRAPEANG (KRAPCUB SRAKA TREI)
PREI NOKOR
Prei Nokor
CHI-MUH THMEI (KPG.KO)
BARACH
PHSARDEK
MOATCHRUK
MoatChruk
BAREA (PREAH SI KEA)
Barea (Preah Sukea)
MI SA
Mesa
PEAM
Peam
Kaoh Tunsay
Kaoh Trall
Barach
PsarDek
Lunghaor
LUNG HAOR
PREK RUSSEI
Prek Russei (Kampul Meas)
Kaoh Koung (Dambak Kaong)
KAOH KOUNG (DAMBAK KAONG)
O Kabb
Kpg.Russei (Phsom Ambeus)
KPG. RUSSEI (PHSOM AMBEUS)
Kramoun Sâ (Reachea)
Kaoh Thom
Kaoh Trei
Kaoh Rai
Kaoh Nam Du
KRAMOUN SÂ (REACHEA)
Preah Trapeang
PREAH TRAPEANG
Khleang (Basak)
KHLEANG (BASAK)
POLLEAV (POTHILEU)/ TOEK KHMAU
Polleav (Pothileu)
Toek Khmau
Kaoh Tralach
Pt. of Toek Khmau (Cape of Cambodia)
កម្ពុជាក្រោម
KAMPUCHEA KROM
(COCHIN-CHINA)
SOUTHEAST ASIA
KAMPUCHEA KROM




ចក្រភពខ្មែរ ក្នុងគ.ស. ១២០០ (DR. Sardesai សាកលវិទ្យាល័យ
កាលីហ្វ័រនីញ៉ា L.A.)


ភ្នំ បាដែង
អង្គរបុរី ( តាកែវ )
វាលភក់
ព្រៃ នគរ
កំពង់ស្រកាត្រី
មេ ស
មាត់ជ្រូក
អូរកែវ
ក្រមួន ស
ព្រែកត្រពាំង
ឃ្លាំង ( បាសាក់ )
ជ្រោយកម្ពុជា
ស្ថានីយ៍ សម័យនគរភ្នំ
( អាណាចក្រ ហ្វូណន )
សតវត្សទី ១ _ ៧
មាត្រដ្ឋាន ៖ 1/4.000.000 ᵉ



ស្រីទេព
វត្តភូ
មាត្រដ្ឋាន :
1
10.000.000
ព្រំដែនបច្ចុប្បន្ន
អាណាចក្រ ភ្នំ




ផែនទីខ្មែរ ឆ្នាំ ៩៦០ គ.ស មុនកំណើត
នៃប្រទេសថៃ ឡាវ និង វៀតណាមខាងត្បូង


វេទិកាសាធារណៈ ស្តីពី ទឹកដីខ្មែរកម្ពុជាក្រោម
រៀបចំដោយ អង្គការ សមាគមខ្មែរកម្ពុជាក្រោម
រាជធានីភ្នំពេញថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៤
PUBLIC FORUM ON KAMPUCHEA KROM
សហគមន៍ខ្មែរកម្ពុជាក្រោម The Khmer Kampuchea Krom Community B.E.2558 A.D.2014
www.khmerkromngo.org



ទឹកដីកម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរ


ខ្មែរលើ ខ្មែរកណ្តាល ខ្មែរក្រោម គឺជាខ្មែរតែមួយ

ខ្មែរលើ ខ្មែរកណ្ដាល ខ្មែរក្រោម គឺជាខ្មែរតែមួយ






**Carte publiée dans "Cambodge" édité par le Ministère de l' Information du Cambodge (1962)**




ផែនទីបង្ហាញប្រទេសឡាជីគោក និងប្រទេសឡាទឹកលិចក្នុងរវាង គ.ស ៨០០

(DR. Sardesai សាកលវិទ្យាល័យ កាលីហ្វ័រនីញ៉ា L.A.)




ទីតាំងរបស់ នគរភ្នំ ពីសតវត្សរ៍ទី១ ដល់ទី៦